# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0052**

## សម្ភាសន៍ជាមួយឈ្មោះ ដួង ជុន ភេទប្រុស អាយុ៥៣ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម« យោធា»

## មុខងារបច្ចុប្បន្ន«កសិករ»

## ស្រុកកំណើតនៅភូមិចេក ឃុំភ្នំស្រួច ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

## រស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០១:០៧:៣៧

## ៣០ទំព័រ

វណ្ណៈ: ចឹងខ្ញុំសូមណែនាំខ្លួនខ្ញុំម្ដងទៀតថា ខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលហើយខ្ញុំមកដល់ស្រុកម៉ាឡៃម៉ានេះ មានបំណងចង់សរសេរសៀវភៅទាក់ទងពីស្រុកម៉ាឡៃ ។

ជុន : បាទ ។

វណ្ណៈ: ចឹងបទសម្ភាសន៍ជាពូហ្នឹងខ្ញុំមានថតសម្លេង ថតជារូបភាពរបស់ពូ ខ្ញុំចង់បានសម្លេងពូខ្ញុំអាចសរសេរជាសៀវភៅប្រវត្តិសាស្ត្រទុកឲ្យក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិម៉ាឡៃ តើពូអនុញ្ញាតទេ?

ជុន : មិនអីទេ ។

វណ្ណៈ: ចឹងមិនអីទេ?

ជុន : បាទ! ខ្ញុំឃើញបានចូលក្នុងស្រុកម៉ាឡៃហ្នឹងខ្ញុំអរណាស់ ព្រោះបានជួយប្រជាជនយើងខ្ញុំដែលធ្លាប់នៅពីមុនមកណាស់ មានការលំបាកមែនការដែលនៅក្នុងព្រៃកន្លងមកវេទនាមែន ។

វណ្ណៈ: ចឹងវេទនាយ៉ាងម៉េចចាំពូជួយរៀបរាប់?

ជុន : វេទនាជីវភាពក្នុងការរស់នៅមានការខ្វះខាតដែរ តែមិនខ្វះខាតឲ្យធំដុំទេ ដួនកាលនៅជុំវិញហ្នឹងមានការខ្វះខាតដែរ តែវាមិនពិបាកអីណាខ្លាំងទេ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូសិន តើពូមានឈ្មោះអីទៅ?

ជុន : ដួង ជុន ។

វណ្ណៈ: ចឹងពូអាយុប៉ុន្មានហើយ?

ជុន : អាយុ៥៣ហើយ ។

វណ្ណៈ  ចឹងប្រពន្ធពូឈ្មោះអីដែរ?

ជុន  :  ឈ្មោះ  គាញ  សារី ។

វណ្ណៈ  អាយុប៉ុន្មានដែរ?

ជុន  :  អាយុ៩២ឆ្នាំ ។

វណ្ណៈ  មានកូនប៉ុន្មាននាក់?

ជុន  :  ខ្ញុំមានកូន៧នាក់ ។

វណ្ណៈ  ស្រី  ប៉ុន្មានប្រុសប៉ុន្មាន?

ជុន  :  ស្រីមួយប្រុសប្រាំមួយ ។

វណ្ណៈ  ចឹងឪពុកពូឈ្មោះអីទៅ?

ជុន  :  ឈ្មោះឃួន  មុត ។

វណ្ណៈ  ចឹងម្ដាយ?

ជុន  :  ម្ដាយឈ្មោះ  ជិន  ភឹន ។

វណ្ណៈ  ចឹងគាត់ទាំងពីរនៅរស់ឬមួយស្លាប់ហើយ?

ជុន  :  គាត់ស្លាប់អស់ហើយ ។

វណ្ណៈ  ចឹងស្លាប់អស់ហើយ?

ជុនៈ  បាទ ។

វណ្ណៈ  ចឹងពូមានបងប្អូនប៉ុន្មាននាក់?

ជុន  :  បងប្អូនមាន៥នាក់ ។

វណ្ណៈ  ទាំងអស់ប៉ុន្មានបងប្អូនបង្កើតពូ?

ជុនៈ  ៥នាក់ហ្នឹងហើយ ។

វណ្ណៈ  នៅរស់ទាំងអស់ចឹង?

ជុន  :  ស្លាប់មួយហើយ ។

វណ្ណៈ  ចឹងស្លាប់មួយ?

ជុនៈ  បាទ ។

វណ្ណៈ  ពូប្រកបមុខរបរអីដែរ?

ជុន  :  ខ្ញុំធ្វើស្រែបន្តិចបន្តួចនិងធ្វើចំការ ។

វណ្ណៈ  ស្រុកកំណើតពូ?

ជុន  :  នៅខេត្តកំពង់ស្ពឺ?

វណ្ណៈ៖ នៅភូមិអី?

ជុន ៖ ភូមិបេក ឃុំភ្នំស្រួច ។

វណ្ណៈ៖ ស្រុក?

ជុន ៖ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

វណ្ណៈ៖ ចឹងឥឡូវពូនៅភូមិអី?

ជុន ៖ ឥឡូវនៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ៖ ចឹងខ្ញុំចង់ឲ្យពូនិយាយរៀបរាប់ប្រវត្តិផ្ទាល់ខ្លួនថានៅជាមួយឪពុកម្ដាយយ៉ាងម៉េច? ហើយចូលរៀនបានត្រឹមណា? ហើយបន្ទាប់មកធ្វើការនៅណា? ហើយបានធ្វើអ៊ីខ្លះ?

ជុន ៖ កាលនៅពីតូចឆ្ងកាត់វែងណាស់ ។

វណ្ណៈ៖ បាទ ។

ជុន ៖ ខ្ញុំនៅកាលពីតូចនៅជាមួយឪពុកម្ដាយខ្ញុំក្រណាស់ ធ្វើស្រែចំការនៅខេត្តកំពង់ស្ពឺមើលឃើញស្រាប់ហើយ ស្រែមិនដែលឃើញល្អទេ កាលខ្ញុំនៅជាមួយគាត់ស្រែច្រើនដែរ មួយស្រែៗច្រូតមិនដឹងជានៅឯណាទេ ស្ទូងបណ្ដើរភ្ជួរបណ្ដើរបាន តែមិនបានភ្ជួរបណ្ដើរស្ទូងបណ្ដើរទេរឹងបាត់ខេត្តកំពង់ស្ពឺហ្នឹង នៅជាមួយគាត់យូរដែរ ដល់ឆ្នាំ៧៣ខ្ញុំចេញពីគាត់រហូតមក ដូចថាខាងតស៊ូពីមុនមកនោះ កាលហ្នឹងនៅក្មេងៗទេ ព្រោះកំពង់តែរៀននោះ តែកាលហ្នឹងមិនដឹងជាថ្នាក់ទីប៉ុន្មានតែកាលហ្នឹងរៀនជ្រៅដែលហើយ ដល់រៀនៗទៅគេថាប្រមូលក្មេងឲ្យធ្វើកងទ័ពការពារ គេថាកងទ័ពរំដោះ គេនាំមកចេះតែតស៊ូៗទៅរហូតមិនដែលជួបម៉ែឪទេ ។

វណ្ណៈ៖ ចឹងចេញពីម៉ែឪតាំងពីឆ្នាំ៧៣?

ជុន ៖ ចេញតាំងពីឆ្នាំ៧៣រហូត ។

វណ្ណៈ៖ ចឹងពូគិតមើលថារៀនបានប៉ុន្មានឆ្នាំបានពូចេញទៅហ្នឹង?

ជុន ៖ រៀនបានប្រហែលជាពីរឆ្នាំដឹង ។

វណ្ណៈ៖ រៀនកាលហ្នឹងប្រហែលជាបានទី៩ដែរ?

ជុន ៖ មិនដឹងជាទីប៉ុន្មានទេ រៀនកាលហ្នឹងមិនដែលមានលេខអីទេ ចេញពីសាលាមករៀននៅក្នុងព្រៃទៀត ។

វណ្ណៈ៖ ចឹងមានរៀននៅក្នុងព្រៃទៀត?

ជុន ៖ បាទ! ។

វណ្ណៈ៖ ចឹងកាលពូចូលនៅឆ្នាំ៧៣ហ្នឹង ពូចូលធ្វើនៅកន្លែងណា?

ជុន ៖ នៅកងទ័ព ។

វណ្ណៈ  កងទ័ពហ្នឹងនៅកន្លែងណា?

ជុន  :  នៅមន្ទីរវីកហ្វ៊ីនហ្នឹងតែម្តងនៅកំពង់ឆ្នាំងមិនមែនទេ  នៅប៉ុរវែឆ្នាំង ។

វណ្ណៈ  ចឹងនៅក្នុងខេត្តកំពង់ស្ពឺដដែល?

ជុន  :  នៅក្នុងខេត្តកំពង់ស្ពឺដដែល ។

វណ្ណៈ  ចឹងខាងចលនាខ្មែររំដោះហ្នឹងដែលវៃជាមួយទាហានលន់  នល់ហ្នឹងច្រើនទេ?

ជុន  :  មានច្រើនណាស់  មានតាំងពីណាណី  មានតាំងពីតាកែវ  កំពតមកប្រមូលរៀននៅហ្នឹង ។

វណ្ណៈ  ចឹងកាលហ្នឹងគ្រូមកពីណាជាអ្នកមកបង្ហាត់?

ជុន  :  មិនដឹងជាគ្រូមកពីណាជាអ្នកមកបង្ហាត់ទេ ។

វណ្ណៈ  កាលហ្នឹងមានគ្រូជនជាតិវៀតណាមទេ?

ជុន  :  អត់មានទេ  មានតែខ្មែរទេ ។

វណ្ណៈ  ចឹងកាលហ្នឹងនៅកំពង់ស្ពឺមានតំបន់ប៉ុន្មានហើយភូមិភាគអី?

ជុន  :  មិនជាតំបន់ប៉ុន្មានទេ    តែភូមិភាគបញ្ចឹមកាលហ្នឹងតូចៗតែចេះចេញៗទៅរហូតដល់រំដោះភ្នំពេញ ជួបម៉ែឪបានប៉ុន្មានទេ  ក៏ចេញមករហូតមកដល់ឥឡូវហ្នឹងបណ្តោយ ។

វណ្ណៈ  កាលហ្នឹងពូនៅកំពង់ស្ពឺហាត់ហើយវៃចូលភ្នំពេញអីហ្នឹង?

ជុនៈ  កាលហ្នឹងបំពាក់អាវុធហើយ ។

វណ  :  វៃជាមួយទាហានខាងណាទៅ?

ជុនៈ    វៃជាមួយទាហានលន់  នល់ ។

វណ្ណៈ    កាលវៃជាមួយទាហានលន់    នល់ហ្នឹងខាងទាហានខ្មែរក្រហមហ្នឹងបានអាវុធមកពីខាងណាពូដឹងទេ ?

ជុន  :  អាវុធ      កាលហ្នឹងបានមកពីចិនហើយវៃបានក្នុងចិនជំនួយផងនិងមួយចំនួនបានមកពីការវៃបាន បន្ទាយណាយកមកប្រើទៀតទៅ  គ្រាប់អីហ្នឹងយកបានតាមបន្ទាយណាយកប្រើហ្នឹងឯង ។

វណ្ណៈ  ចឹងនៅពេលដែលវៃឈ្នះទាហានលន់  នល់?

ជុន  :  យករបស់ហ្នឹងប្រើមានទាំងគ្រាប់ទាំងកាំភ្លើង  ឲ្យតែវៃឈ្នះត្រង់ណាយកចែកគ្រប់ច្រក ។

វណ្ណៈ  ចឹងនៅពេលហ្នឹងខាងខ្មែរក្រហមនិងខាងលន់  នល់មានស្លាប់ដូចគ្នាឬមួយយ៉ាងម៉េច?

ជុន  :  ខាងក្នុងស្លាប់ច្រើនខាងលន់  នល់ស្លាប់ច្រើនជាង  តែកាលពេលអាមេរិចយកយន្តហោះមកទម្លាក់ ស្រុកខ្មែរកាលជួយលន់  នល់  ហ្នឹងខ្មែរស្លាប់ច្រើន  អត់មានរើសទេមិនថាយោធាមិនថាប្រជាជន អ្នកនៅតាមភូមិទម្លាក់ម្តងៗ  ទាំងយប់ទាំងថ្ងៃ  គ្មានពេលសម្រាក់ទេ ។

វណ្ណៈ  បាទ ។

ជុន ៖ ជួនកាលមួយថ្ងៃមួយយប់រត់ទាល់តែភ្លឺក៏មាន ថ្ងៃឡើងទល់ល្ងាចក៏មានដែរ ទម្រាក់ទាំងយប់ទាំងថ្ងៃ តែកាលហ្នឹងចេញតែសំណាងដែលបានរស់មកដល់ឥឡូវ ហើយទម្រាក់ម្ដងៗមិនមានពេលសំរាកទេ មិនដែលបាននៅកណ្ដាលវាលទេ នៅក្នុងព្រៃរហូត ។

វណ្ណៈ៖ ចឹងនៅឆ្នាំ៧៣-៧៤ពូវៃចូលភ្នំពេញហ្នឹងតាមមុខសញ្ញាណាតាមផ្លូវជាតិលេខប៉ុន្មាន?

ជុន ៖ វៃចូលតាមផ្លូវជាតិលេខ៥ ។

វណ្ណៈ៖ ចឹងកាលវៃចូលភ្នំពេញហ្នឹងពូមានបានវៃចូលភ្នំពេញទេ?

ជុន ៖ បាទ!វៃចូលផ្ទាល់ ។

វណ្ណៈ៖ ចឹងនៅពេលដែលចូលដល់ភ្នំពេញដំបូងពូមានឃើញសកម្មភាពយ៉ាងម៉េចខ្លះ?

ជុន ៖ ឃើ!សំបើមណាស់ដែលប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញហ្នឹង ដើម្បីឲ្យអស់កុំឲ្យកើតតទៅទៀតហ្នឹងនៅពេលដែលជម្លៀសប្រជាជនចេញអស់ហើយ បានគេដកទាហានឲ្យទៅឈរជើងនៅខេត្តតាកែវនោះ ទៅកសាងខាងផ្ទាល់ជាតិម្ដង ទាហានទៅតែកសាងធ្វើផ្ទាល់ម្ដង ។

វណ្ណៈ៖ ចឹងនៅពេលជម្លៀសប្រជាជនចេញពីភ្នំពេញហ្នឹងមានស្លាប់ទេ?

ជុន ៖ អត់មានស្លាប់ទេ ។

វណ្ណៈ៖ ចឹងពូចូលដល់ទីក្រុងភ្នំពេញនៅម៉ោងប៉ុន្មាន ហើយស្មានណាដែរ?

ជុនៈ ឃើពេល...។

វណ្ណៈ ពេលព្រឹកឬពេលយប់?

ជុន ៖ ចូលនៅពេលព្រឹកតែមិនចាប់អារម្មណ៍មិនដឹងជាម៉ោងប៉ុន្មានដែរ ។

វណ្ណៈ ចឹងពេលព្រឹកចូលដល់ភ្នំពេញទាំងស្រុងតែម្ដង?

ជុនៈ ហ្នឹងហើយ ។

វណ្ណៈ៖ ចឹងខាងយោធាហ្នឹងប្រកាសឲ្យប្រជាជនចេញទៅក្រៅក្រុងទៅតាមជនបទ?

ជុន ៖ ហ្នឹងហើយឲ្យចេញទៅតាមជនបទ ។

វណ្ណៈ៖ ចឹងប្រហែលជាប៉ុន្មានថ្ងៃប្រជាជនចេញអស់ក្រុង?

ជុន ៖ យូរដែលប្រហែលជាមួយអាទិត្យដែរ ។

វណ្ណៈ៖ នៅពេលដែលប្រជាជនចេញអស់ទីក្រុងភ្នំពេញស្ងាត់ឬមានសភាពយ៉ាងម៉េចដែរ?

ជុន ៖ ស្ងាត់ ។

វណ្ណៈ ចឹងនៅភ្នំពេញស្ងាត់?

ជុនៈ បាទ ។

វណ្ណៈ ហើយកំលាំងយោធាមកពីគ្រប់កន្លែងទាំងអស់?

ជុនៈ មកនៅតាមទីក្រុងទាំងអស់ ។

វណ្ណៈៈ ចឹងបើតាមពូដឹងកងកំលាំងខ្មែរក្រហមចូលភ្នំពេញហ្នឹងមានប៉ុន្មានកងពល?

ជុន ៈ ដឹងកំលាំងកាលហ្នឹងមានបួនកងពល អេ!មិនមែនបួនកងពលទេមានច្រើន ។

វណ្ណៈៈ ចឹងពូនៅកងពលណា?

ជុន ៈ នៅកងពលទី១ ។

វណ្ណៈៈ ចឹងកងពលទី១កាលហ្នឹងពីណាជាអ្នកដឹកនាំ?

ជុន ៈ កាលហ្នឹងមានតា ឡូញ ។

វណ្ណៈៈ មានពីណាទៀត?

ជុន ៈ មានអ៊ឹសឿង តមកទៀតតា ម៉ុកចឹងមក ប្រពន្ធគាត់និយាយ“ថា តា ម៉ុកកងពលទី២ទេ” មែនតា ម៉ុកកងពលទី២ តែគាត់រួមចូលហ្នឹងដែរ ។

វណ្ណៈៈ ចឹងកាលហ្នឹងមានស្គាល់តា ណាត តាពីនអីទេ?

ជុន ៈ អត់ទេ ។

វណ្ណៈ ខាងហ្នឹងខាងកោះធំ?

ជុនៈ កាលនោះ ។

វណ្ណៈ ខាងខេត្តកណ្តាល?

ជុនៈ ខាងខេត្តកណ្តាលនោះ ។

វណ្ណៈៈ ចឹងកាលពូនៅភ្នំពេញបានរយៈពេលប៉ុន្មានឆ្នាំខែដែរ?

ជុន ៈ កាលនៅភ្នំពេញខ្ញុំនៅខាងកាបូលទេ នៅកាបូលហ្នឹងការពារគ្រាប់យន្តហោះដែលទុកចោលហ្នឹង ។

វណ្ណៈៈ ចឹងនៅការពារកាបូលហ្នឹងរយៈពេលប៉ុន្មាន?

ជុន ៈ នៅកាបូលហ្នឹងរយៈពេលមួយឆ្នាំ ។

វណ្ណៈៈ ចឹងនៅមួយឆ្នាំអង្គការបញ្ជូនទៅណាទៀត?

ជុន ៈ បញ្ជូនមកនៅខេត្តកោះកុង ។

វណ្ណៈៈ ចឹងនៅកោះកុងហ្នឹងគេឲ្យមកធ្វើអីដែរ?

ជុន ៈ នៅកោះកុងគេឲ្យមកធ្វើពេទ្យ ។

វណ្ណៈ ចឹងចេញពីទាហានពេទ្យម្តង?

ជុនៈ បាទ ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូថាបានរៀនតិចតួចហេតុអីបានជាពូបានធ្វើពេទ្យ?

ជុន ៖ កាលសម័យហ្នឹងដឹងស្រាប់ហើយឲ្យតែអ្នកណារៀងគ្រាន់បន្តិចគេឲ្យទៅធ្វើពេទ្យហើយ មានដុកទ័រគេចេះជួយយ៉ាងម៉េច ជួយចាក់គេ ជួយដាំបាយ មើលថែចាក់ថ្នាំក៏ចេះទៅ ។

វណ្ណៈ៖ ចឹងនៅជំនាន់ខ្មែរក្រហមអត់មានរើសសញ្ញាប័ត្រអីទេ?

ជុន ៖ អត់ទេ មិនចាំបាច់រើសចេះមិនចេះទេឲ្យតែយើងមានស្មារតី កាលហ្នឹងរៀនចាំ មានដុកទ័របង្រៀន ។

វណ្ណៈ៖ ចឹងពូធ្វើពេទ្យបានរយៈពេលប្រហែលជាប៉ុន្មានឆ្នាំនៅកោះកុងហ្នឹងបានពូរត់តែម្តង?

ជុន ៖ ខ្ញុំធ្វើរហូតដល់រត់តែម្តង ធ្វើពេទ្យពី៧៧ដល់៧៩តែម្តងយើងរត់ ។

វណៈ ចឹងធ្វើពេទ្យតាំងពីឆ្នាំ១៩៧៧?

ជុនៈ បាទ ។

វណ្ណៈ៖ ចឹងការងារពេទ្យហ្នឹងព្យាបាលតែកងទ័ពឬមួយព្យាបាលប្រជាជនដែរ?

ជុន ៖ ព្យាបាលចំរុះ មិនថាប្រជាជនមិនថាទាហានមិនរើសមុខទេ ។

វណ្ណៈ៖ ចឹងកាលដែលពូនៅភ្នំពេញមួយឆ្នាំហ្នឹង ពូមានសង្កេតឃើញមានការចាប់មនុស្សអីទេ?

ជុន ៖ កាលហ្នឹងនៅភ្នំពេញខ្ញុំដឹងតែមានចាប់ដែរ តែទាល់អ្នកហ្នឹងមានស្រីទាក់ទងគ្នាគេចាប់ព្រឹប ទោះបីបងប្អូនក៏ដោយ ឲ្យតែស្រីប្រុសនិយាយគ្នាមិនបានទេ មានអ្នកតាមដានថាអានោះទាក់ទងស្រីទៀតហើយចឹងណាស់ ថ្នាក់ណាក៏ដោយថ្នាក់តូចថ្នាក់ធំក៏ដោយឲ្យតែនិយាយជាមួយស្រីៗ ។

វណ្ណៈ៖ ចឹងយើងមិនអាចនិយាយលេងជាមួយស្រីៗបានទេ?

ជុន ៖ និយាយមិនបានទេ ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូនៅតូចដែរ?

ជុន ៖ កាលខ្ញុំវ៉ៃចូលទីក្រុងភ្នំពេញហ្នឹង ខ្ញុំអាយុជិត២០ឆ្នាំហើយ ។

វណ្ណៈ៖ ចឹងពូដឹងថាមានការចាប់មនុស្សតែសម្លាប់មិនសម្លាប់ពូមិនដឹងទេ?

ជុន ៖ មិនបានដឹងទេ ។

វណ្ណៈ៖ ចឹងប្រធានពេទ្យនៅកោះកុងហ្នឹងពូមានស្គាល់ប្រធានពេទ្យទេ?

ជុន ៖ ប្រធានពេទ្យនៅកោះកុងហ្នឹងដំបូង តា តូង ដល់អង្គការចាប់ខ្លួនទៅបានផ្លាស់តា វឿន កាលហ្នឹងតាវឿនហើយពីណាទេខាងដុកទ័រ ។

វណ្ណៈ៖ តាវឿនហ្នឹងមកពីខាងណា?

ជុន ៖ តា វឿនដំបូងជាយោធាក្រោយមកកាន់ខាងមន្ទីរពេទ្យវិញ ។

វណ្ណៈ៖ តាវឿនហ្នឹងនៅខាងភូមិភាគណា?

ជុនៈ    គាត់នៅខាងភូមិភាគហ្នឹងដែរ ។

វណ្ណៈៈ ចឹងក្រោយមកមានចាប់គា វៀនទៀតទេ?

ជុន ៈ អត់មានចាប់ទេ ក្រោយមករត់៧៩តែម្តង ។

វណ្ណៈៈ ចឹងចាប់គា តួងហើយគាវៀនចូលមកលែងហ៊ានចាប់ទៀតហើយ?

ជុន ៈ លែងមានចាប់ហើយ ។

វណ្ណៈៈ ចឹងបុគ្គលិកពេទ្យមានប្រហែលជាប៉ុន្មាននាក់?

ជុន ៈ បុគ្គលិកពេទ្យមានប្រហែលជា១៥នាក់ ។

វណ្ណៈៈ ចឹងមានតិច?

ជុន ៈ បាទ!តិច ។

វណ្ណៈៈ ចឹងមានមន្ទីរពេទ្យប៉ុន្មានខ្នង?

ជុន ៈ មានមន្ទីរធំតាំងពីដើមមកតែម្តង ។

វណ្ណៈៈ ចឹងនៅកោះកុងហ្នឹងមានមន្ទីរពេទ្យចាស់?

ជុន ៈ ហ្នឹងហើយមានមន្ទីរពេទ្យចាស់ ។

វណ្ណៈៈ នៅម្តុំណា?

ជុន ៈ នៅកន្លែងចុះពីដែមកហ្នឹង មានដើមស្រល់ច្រើនហ្នឹងចុះពីដំណាក់ស្តេចចុះខាងនេះដំណាក់ស្តេច ។

វណ្ណៈៈ ចឹងនៅកោះកុងពូមិនសូវលំបាកដែរឬយ៉ាងម៉េច?

ជុន ៈ អត់មានលំបាកទេ ។

វណ្ណៈៈ ចឹងយោធាហូបចុកគ្រាប់គ្រាន់?

ជុន ៈ គ្រប់គ្រាន់ ។

វណ្ណៈៈ ចឹងប្រជាជន?

ជុន ៈ ប្រជាជនហូបគ្រប់គ្រាន់ដែរ ។

វណ្ណៈ ចឹងមិនសូវលំបាកទេ?

ជុនៈ មិនសូវលបាកទេ ។

វណ្ណៈៈ ចឹងមានអ្នកខុសគេយកទៅវៃចោលអីដែរ?

ជុន ៈ បាទ!មានចាប់យកទៅបាត់ ឲ្យតែមានបញ្ហាអីអត្តុយចឹងយើងមិនដឹងអីផងគេមកព័ទ្ធចាប់ដាក់ទូក យកទៅបាត់ យកមកក្រោយមកមិនដឹងជាយកទៅណាទេ យកមកកំពង់សោមអីណាទេ ។

វណ្ណៈៈ ចឹងកាលហ្នឹងពូមានបានទៅខាងដើងទឹកទេ?

ជុន ៈ អត់ទេ តែបានដើរលេងតាមសមុទ្រអីមានដើរ ។

វណ្ណៈ ចឹងកាលហ្នឹងពូមិនទាន់រៀបការអីទេ?

ជុន : នៅទេ ទើបមករៀបការនៅក្នុងព្រៃនេះទេ ។

វណ្ណៈ ចឹងកាលហ្នឹងនៅពេលបែកនៅឆ្នាំ៧៩ ហេតុអីបានជាពូមិនរត់ទៅផ្ទះយ៉ាងម៉េបានជាមិនរត់មករកស្រុកកំណើត?

ជុនៈ ចុះមកដូចជានៅក្រុងចឹងមកបើក។ ប៉ុស្តចឹងមកដាច់ប៉ុសតិចយួនចូលពេញហើយដឹង ។

វណ្ណៈ បាទ ។

ជុន : តិចយួនមកហើយរត់ក៏រត់តាមគេតែម្តងមកដឹកថ្នាំពេទ្យសម្ភារៈអីឡើងមកមានសម្ភារវះកាត់សម្រាប់ក្រែងលោមានយោធាមានរបួសត្រូវវះកាត់ចឹងទៅតាមគេរហូតមក ។

វណ្ណៈ ចឹងរត់ដោយសារខ្លាចយួនឬមួយយ៉ាងម៉េច?

ជុន : ខ្លាចយួន គេថាយួនមកខ្លាចគេសម្លាប់ ។

វណ្ណៈ ចឹងក៏អត់បានជួបឪពុកម្តាយទៅ?

ជុន : អត់ ។

វណ្ណៈ រត់បែករហូតទៅ?

ជុនៈ បែករហូត ។

វណ្ណៈ ចឹងរត់ចេញពីកោះកុងមកកាត់តាមផ្លូវណាបានមកដល់ម៉ាឡៃហ្នឹង?

ជុន : អត់មានផ្លូវទេកាត់ព្រៃរហូតតែម្តង កាត់ព្រៃចូលទៅថៃបណ្តោយរត់អត់បាយប្រហែលជាមួយខែ បានចូលនៅដីថៃប្រហែលជាកន្លះឆ្នាំបានគេដឹកឡានមកដីខ្មែរវិញ ។

វណ្ណៈ ចឹងអត់បាយហូបស្លឹកឈើទៅ?

ជុន : ហូបស្លឹកឈើ ជួនហូបផ្លែកោងកាងតាមសមុទ្រជួនពុលមួយសារទៀត ។

វណ្ណៈ ចឹងមានអ្នកពុលស្លាប់ទេ?

ជុន : អត់ទេ ។

វណ្ណៈ ចឹងមានអ្នកចាញ់តាមផ្លូវស្លាប់ទេ?

ជុន : អត់មានអ្នកណាចាញ់ទេ ច្រើនអ្នករត់ ។

វណ្ណៈ ចឹងរត់មកប៉ុន្មាននាក់ជាមួយពូ?

ជុន : មកជាង១០ នាក់?

វណ្ណៈ ចឹងនៅទាំងអស់?

ជុន : ស្លាប់ខ្លះហើយ ។

វណ្ណៈ ស្លាប់ពេលរត់ឬមួយស្លាប់ក្រោយមកទៀត?

ជុន : ស្លាប់ពេលដែលវៃតាមព្រំដែនហើយស្លាប់តៗអស់ទៅ ។

វណ្ណៈ: ចឹងពូបានមករស់នៅម៉ាឡៃហ្នឹងនៅឆ្នាំណាដែរឆ្នាំ៧៩ហ្នឹងដដែលឬឆ្នាំ៨០ ?

ជុន : មុនដំបូងមកនៅខ្សែមនោះ នៅ៨១ នៅចក្រីនោះ ។

វណ្ណៈ: ចឹងកាលហ្នឹងរត់ទៅខាងចក្រីទេ?

ជុន : ហ្នឹងហើយតែគេដឹកមកដាក់ត្រឹមខ្សែមនោះថៃដឹកមក ។

វណ្ណៈ: ចឹងកាលនៅចក្រីហ្នឹងមានវៃជាមួយយួនទេ?

ជុន : វៃជាមួយយួនតែខ្ញុំនៅតែធ្វើពេទ្យតាមកងដដែល តែកាលហ្នឹងធ្វើពេទ្យផងវៃផងជាមួយគ្នា
អាកាបូបក៏ស្ពាយកាំភ្លើងក៏កាន់ដែរ ។

វណ្ណៈ: ចឹងនៅខាងចក្រីហ្នឹងអត់មានប៉ុរាទេ មានតែខ្មែរក្រហមទេ?

ជុន : មានតែខ្មែរក្រហម ។

វណ្ណៈ: ចឹងកាលហ្នឹងខាងចក្រីនេះមេបញ្ជាការពីណា?

ជុន : ខាងចក្រីនេះមេបញ្ជាការមានតា កន ។

វណ្ណៈ: ឋានៈកងពល?

ជុន : ហ្នឹងហើយកងពលមេធំ ។

វណ្ណៈ: តា កនហើយមានពីណាទៀត?

ជុន : ក្រោយមកមានតាភាពយើងនេះ ។

វណ្ណៈ ចឹងមានសុខភាព?

ជុនៈ បាទ ។

វណ្ណៈ: ចឹងតា កនគាត់នៅរស់ទេ?

ជុន : គាត់នៅរស់រាល់ថ្ងៃហ្នឹង ។

វណ្ណៈ: ចឹងកាលហ្នឹងកំលាំងខ្មែរក្រហមវៃទៅមកៗចឹងសម្ភារខ្មែរក្រហមកាលពី៧៩ដល់៨០ - ៨១ -
៨២ - ៨៣ហ្នឹងទទួលសម្ភារពីខាងណាមក?

ជុន : កាលហ្នឹងមិនទៀងមិនដឹងទទួលពីខាងណាមកដែរ វាចំរុះមិនថាយកមកពីថៃមិនថាយកមកពីចិន
មិនថាមកពីណាដឹងតែយកមកប្រគល់ឲ្យកងទ័ព ។

វណ្ណៈ: កាលហ្នឹងខាងទាហានខ្មែរក្រហមមានប្រាក់ខែទេ?

ជុន : កាលហ្នឹងមិនមានទេ មិនដែលស្គាល់ប្រាក់ខែយ៉ាងម៉េច ។

វណ្ណៈ: ចឹងតាំងពី៧៩ដល់សមាហរណកម្មនៅឆ្នាំ៩៦ហ្នឹងខាងខ្មែរក្រហមមិនមានប្រាក់ខែទេ?

ជុន ៖  អត់មានទេ    មិនដែលមានប្រាក់ខែបើយ៉ាងម៉េចទេ    កាលនៅសង្គ្រាមបើកពីរជងបើកខាងជីវភាពបានម្នាក់១៥រៀលម្តងក្រៅពីហ្នឹងមិនដែលឃើញទេ ។

វណ្ណៈ៖  ចឹងឥឡូវមានប្រាក់ខែចូលនិវត្តន៍មែនទេ?

ជុន ៖  បាទ!ចូលនិវត្តន៍ហើយ ។

វណ្ណៈ  ចឹងបានប្រាក់ខែសង្គមកិច្ចដែរ?

ជុនៈ   បាទ ។

វណ្ណៈ៖  ចឹងបានប្រាក់ខែប៉ុន្មាន?

ជុន ៖  បានប្រាក់ខែ២០០០០០ទៅ២១០០០០រៀល ។

វណ្ណៈ៖  ចឹងកាលសម័យខ្មែរក្រហម៧៩ដល់៩៦មិនមានប្រាក់ខែតែមានរបបហូបចុកគ្រប់គ្រាន់?

ជុនៈ   គ្រប់គ្រាន់ ។

វណ្ណៈ  មិនឲ្យប្រពន្ធកូនលំបាកទេ?

ជុន ៖  មានរបបហូបចុកគ្រប់គ្រាន់មិនឲ្យប្រពន្ធកូនលំបាកទេ  ពិបាករឿងប្តីបន្តិច ។

វណ្ណៈ៖  លំបាករឿងប្តីយ៉ាងម៉េច?

ជុន ៖  ចុះកាលហ្នឹងប្តីចេញទៅវៃខាងមុខ  យើងចាញ់ហើយគេដេញឲ្យយើងទៅវៃទៀត ។

វណ្ណៈ  ចឹង?

ជុនៈ   វាពិបាកណាស់រឿងទាហាន  ចាញ់គេហើយគេឲ្យទៅទៀត ។

វណ្ណៈ៖  ចឹងកាលហ្នឹងមានខ្លាចដាន់មីនទេ?

ជុន ៖  បេះតែខ្លាចហើយមិនដឹងជាធ្វើម៉េចបើចឹងទៅហើយ ។

វណ្ណៈ  ចឹងខ្វះស្លាប់ៗទៅ?

ជុនៈ   រឿងស្លាប់វាមិនទៀង ។

វណ្ណៈ៖  ចឹងកាលហ្នឹងមានយួនស្លាប់ច្រើនទេ  តាមពូដឹង?

ជុន ៖  កាលហ្នឹងមានយួនស្លាប់ច្រើនដែរ ។

វណ្ណៈ៖  ចឹងខ្មែរខាងក្នុងមានស្លាប់ច្រើនដែរ?

ជុន ៖  មានស្លាប់ច្រើនដូចគ្នាឲ្យតែមកប៉ះគ្នាដឹងតែមានរាប់ ។

វណ្ណៈ៖  ចឹងធ្វើពេទ្យយ៉ាប់ដែរ?

ជុន ៖  យ៉ាប់ដែលព្រោះតាមយោធារហូត  បើឡើងទៅវៃទីតាំងមានកំលាំងតែ៣ទៅ៤នាក់ទេ ។

វណ្ណៈ៖  មានតិច?

ជុនៈ   ចុះកំលាំងមានតិចនោះ ។

វណ្ណៈ ចឹងមានបីទៅបួននាក់ទៅវៃគេមានវៃសាបសិបនាក់?

ជុន ៈ វៃចុះស្ពាយមួងដប់គ្រាប់វ៉ាន់នោះម្នាក់ ដល់ពេលកាន់ទៅដល់ដាក់គ្រាំៗដេកព្រួយ ស្ងាត់គ្រាប់ព្រឹកឡើងដើរលេងចឹងមានពីណាមកធ្វើអី ចឹងបានយើងនៅវៃលើកទ័ពមួងៗរកយ៉ាងម៉េចមិនឃើញ គេចតែបន្តិចមកនៅខាងក្រោយវាបាត់វាវៃក្រោយក៏វៃទៅនៅដេក ។

វណ្ណៈ ចឹងគ្នាតែពីរបីនាក់?

ជុនៈ បាទ ។

វណ្ណៈៈ ចឹងពូនៅចក្រីហ្នឹងដល់ឆ្នាំណាបានមកដល់ស្រុកម៉ាឡៃហ្នឹង?

ជុន ៈ ប្រហែលជាឆ្នាំ៩១-៩២ «ប្រពន្ធ» នៅចក្រីតាំងពីឆ្នាំ៧៩-៨០-៨២និង៨៣ចូលទៅជុំរំហើយបានសុំគេមកខ្មែរវិញ រត់ចូលជំរំហើយសុំគេចេញមកខ្មែរវិញគេតាមចាប់ទៀតខ្ញុំគេចរឹបគេចង់ឲ្យយើងឡើងទៅមុខវិញ ឡើងទៅវៃវិញ គេថាអត់មានកំលាំងទេ ទៅជួយការពារទឹកដីខ្ញុំថាទឹកដីៗមិនដឹងទេរកកន្លែងគេចសិន គេចៗទៅមកចូលនៅនេះដុក ។

វណ្ណៈ ចឹងមកដល់នេះនៅឆ្នាំណា?

ជុនៈ មកដល់នេះប្រហែលជាឆ្នាំ៨៥ «ប្តី»ថា៩០ហើយ«ប្រពន្ធថាយើងចេញពីកាង៉ុក៨៥ដីថៃ ។

វណ្ណៈ ឥឡូវខ្ញុំសួរកាត់បន្តិចសិន កាលដំបូងមិនទាន់មកដល់ម៉ាឡៃនៅចក្រីមែនទេ?

ជុនៈ បាទ ។

វណ្ណៈៈ ចឹងនៅចក្រីមីងនិងពូរៀបការហើយឬនៅ?

ជុន ៈ ខ្ញុំការហើយ ។

វណ្ណៈៈ ការឆ្នាំណា?

ជុន ៈ ឆ្នាំ៨១ ។

វណ្ណៈៈ ចឹងការឆ្នាំ៨១ហហ្នឹងមានលោកសង្ឃមានអាចារ្យទេ?

ជុន ៈ អត់មានទេ ចាប់គូរដែរ?

វណ្ណៈៈ ចឹងចាប់គូរប៉ុន្មានគូរកាលហ្នឹង?

ជុន ៈ ខ្ញុំការ៦គូរ តែគេស្លាប់អស់ហើយនៅតែពីរគូរនៅល្ហាគៀមួយគូរ តែឥឡូវមិនដឹងជាយ៉ាងម៉េចទេ ស្ងាត់អស់ហើយ ។

វណ្ណៈៈ កាលហ្នឹងមានពីណាចូលរួមមានគណៈអធិបតីអីមានពីណាខ្លះ?

ជុន ៈ កាលហ្នឹងមាន តា កន និងប្រធានកងវរៈហ្នឹង ។

វណ្ណៈៈ ចឹងពូមើលឃើញមីងចឹងស្មើរទៅ អត់មានចាប់គូរដូចជិនាន់បីឆ្នាំទេ?

ជុន ៈ អត់មានទេ ។

វណ្ណៈ ខ្ញុំធ្លាប់ជួបសម្ភាសន៍នៅជំនាន់បីឆ្នាំចាប់គូរយកតែម្តង?

ជុន ៖ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងមានស្រីៗមិនពេញចិត្តលេបថ្នាំសម្លាប់ខ្លួនមានចឹង?

ជុន ៖ មានមែននៅឆ្នាំ៧៧-៧៨មានមែន ដូចថាឥឡូវយោធាមកដាក់តម្រៀបជាជួរចឹងដូចថា៥០នាក់ ចឹងទៅយកនារី៥០ដែលមក នរណាដើរមុនគេគូរមុនចឹងទៅអត់មានសិទ្ធរើសទេ ។

វណ្ណៈ ចឹងគូរតាមលេខរៀងទៅ?

ជុនៈ ចាស!មានលេបថ្នាំស្លាប់ដូចថាស្រឡាញ់អ្នកនេះផ្សេង ដល់ទៅរៀបជាមួយលោកឯងផ្សេងចឹង វាលេបថ្នាំទៅ ។

វណ្ណៈ ចឹងសុំដូរទៅ?

ជុន ៖ សុំដូរអី ណាមួយមិនហ៊ានមាត់ផង កាលសម័យហ្នឹងគេចាប់គូរចឹងបើយើងស្រឡាញ់គ្នាពេក គេចាប់យើងដាក់គុកទៀត ។

វណ្ណៈ យ៉ាងម៉េចចឹង?

ជុន ៖ បើយើងមិនស្រឡាញ់គ្នាក៏យកយើងដាក់គុកបើយើងស្រឡាញ់គ្នាពេកយកយើងគុកដែរ គេថា យើងស្រឡាញ់គ្នាភ្លេចការងារ តែខ្លះមិនស្រឡាញ់គ្នាក៏យកយើងដាក់គុកទៀត ខ្ញុំកាលហ្នឹងខ្ញុំ ជាប់ដែរ តែខ្ញុំគេចទៅរួចខ្លួន ។

វណ្ណៈ បាទ ។

ជុនៈ ដល់រួចខ្លួនចឹងទៅខាងប្រុសមិនសុខចិត្ត យកអ្នកផ្សេងមកការឲ្យដែលគេមិនសុខចិត្តគេនៅតែ ទៀមទារការជាមួយខ្ញុំម្ល៉េះហើយគេយកខ្ញុំទៅដាក់កន្លែងអប់រំចឹងទៅណាស់ តែការហ្នឹងបើការ ជាមួយពីណាគឺពីហ្នឹងគេឃើញយើងហើយគេស្នើរតែយើងមិនបានដឹងខ្លួន ។

វណ្ណៈ បាទ ។

ជុនៈ គេការមានតែថ្ងៃទី១០ថ្ងៃទី២០និងថ្ងៃ៣០មានបីថ្ងៃហ្នឹងទេក្នុងសម័យហ្នឹងណាស់ គេយើងគេរួច បីថ្ងៃហ្នឹងរួចហើយ ។

វណ្ណៈ ចឹងគេកំណត់ចឹង?

ជុន ៖ ហ្នឹងហើយឲ្យតែថ្ងៃ១០-២០-៣០ដឹកមកទាំងឡានៗ ហ្នឹងនៅឆ្នាំ៧៧-៧៨ហើយនៅក្រុង បាត់ដំបងផ្ទាល់ ។

វណ្ណៈ ចឹងមានថ្ងៃ១០ថ្ងៃ២០និង៣០?

ជុនៈ បាទ ។

វណ្ណៈ ចឹងអត់មានចាំខែប្រាំងខែវស្សាអីទេ?

ជុន ៖ អត់មានទេ គ្មានខែវស្សាគ្មានប្រាំងអីទេ កំពង់តែធ្វើការក៏ហៅមកដែលកំពង់តែកាប់ដីចឹងក៏ហៅមកដែរ ។

វណ្ណៈ៖ ចឹងអត់មានថ្ងៃសីលទេ?

ជុន ៖ អត់មានសីលអីបើអត់មានវត្តវ៉ាផង កាលហ្នឹងខ្ញុំនៅក្រុងបាត់ដំបងតែម្ដង ឧបមាត្រូវការចឹងគេយកតាមតំបន់មកដូចជាតំបន់៥ តំបន់៧ តំបន់៣ យកមកនៅជុំគ្នានៅបាត់ដំបងហ្នឹងតែម្ដង ដូចថាយោធាមួយឡានយកមកការថ្ងៃ១០ ហ្នឹងហើយមាន៥០ ចឹង ។

វណ្ណៈ៖ បាទ ។

ជុនៈ ៥០ នាក់គេទៅជ្រើសរើសយកពីសហករណ៍មកចឹង ដូចជាតំបន់១ តំបន២ តំបន់៥ អីចឹងទៅ កាលសម័យហ្នឹងគេហៅចឹងលោកគ្រូ ។

វណ្ណៈ បាទ ។

ជុនៈ យកមកដល់ថាគេរៀបចំប៉ុន្មានដូចជា៥០ ចឹងយកនារីមក៥០ មកចុះពីលើឡានមកពូៗ អង្គុយជាជួរចឹងទៅនារីៗ ចុះពីលើឡានមកមួយៗ តាមលំដាប់មកលេខ១ លេខ២ យើងមានរាងចុះពីលើឡានមកតគ្នាមកដាក់មកចាប់គូរចឹងមកអត់មានរើសទេ តែភាគច្រើនមិនសូវខុសគ្នាដែរ ព្រោះយើងខ្លាចស្លាប់រៀងខ្លួន ។

វណ្ណៈ បាទ ។

ជុន ៖ កាលហ្នឹងពូៗក៏ខ្លាចស្លាប់នារីក៏ខ្លាចស្លាប់ម្លោះហើយចេះតែទទួលហើយ ។

វណ្ណៈ បាទ ។

ជុនៈ អត់មានបញ្ហាអីដែរ ។

វណ្ណៈ៖ បាទ ។

ជុន ៖ នៅកន្លែងខ្ញុំមានស្លាប់ហ្នឹងដោយសារចេះទេ ព្រោះយើងនៅកន្លែងឃ្លាំងជាកន្លែងចែកចាយណាស់ហើយគាកុងឡាន ។

វណ្ណៈ៖ ឃ្លាំងស្អីគេ?

ជុន ៖ ឃ្លាំងផលលិតផលសម្រាប់ចែកចាយឲ្យប្រជាជនតែម្ដង ។

វណ្ណៈ៖ ឃ្លាំងអង្ករ?

ជុន ៖ មានអង្ករមានម្ហូបនិយាយរួមសម្ភារស្បៀងនៅលើពួកខ្ញុំទាំងអស់ ដឹកមកពីភ្នំពេញប៉ុន្មានដឹកមកបញ្ចូលឲ្យពួកខ្ញុំទាំងអស់ ។

វណ្ណៈ ឃ្លាំងនៅក្នុងក្រុង?

ជុនៈ ចាស "ប្រពន្ធនិយាយ" ។

វណ្ណៈៈ ចឹងមីងនៅតំបន់ប៉ុន្មាន?

ជុន ៈ ចាស«ប្រពន្ធនិយាយ»កាលដំបូងខ្ញុំនៅតាកែវទេ ខ្ញុំឡើងពីតាកែវមកនៅបាត់ដំបងហ្នឹង ។

វណ្ណៈៈ ចឹងមីងស្រុកកំណើតនៅតាកែវទេ?

ជុន ៈ ចាស«ប្រពន្ធនិយាយ» ។

វណ្ណៈៈ ចឹងមីងមកនៅបាត់ដំបងហ្នឹងនៅឆ្នាំណា?

ជុន ៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំមកកាលឆ្នាំ៧៧ ។

វណ្ណៈ ចឹងកាល៧៧មកបាត់ដំបង?

ជុនៈ ចាស«ប្រពន្ធនិយាយ» ។

វណ្ណៈៈ ចឹងពេលដែលមកដល់បាត់ដំបងហ្នឹងគេហៅតំបន់ឬភូមិភាគអីទៅ?

ជុន ៈ ចាស«ប្រពន្ធនិយាយ»ភូមិភាគពាយ័ព្យ ។

វណ្ណៈៈ ចឹងនៅបាត់ដំបងហ្នឹងមានច្រើនតំបន់?

ជុន ៈ ចាស«ប្រពន្ធនិយាយ»នៅកន្លែងបាត់ដំបងហ្នឹងមិនដឹងជាមានប៉ុន្មានតំបន់ទេ ខ្ញុំមិនសូវជាចាប់អារម្មណ៍ទេខ្ញុំដឹងថាតំបន់៥មកជាយស្វាយស៊ីសាផុននេះជាតំបន់៥ ហើយតំបន់៣នៅក្នុងក្រុងវត់ដំបងតែមួងឬម៉េចទេតំបន់៣ភ្លេចដែរ ។

វណ្ណៈៈ តាមខ្ញុំដឹងនៅសម័យខ្មែរក្រហមមានតែតំបន់៣មួយទេ ដែលប្រជាជនមានហូបគ្រប់គ្រាន់?

ជុន ៈ ចាស«ប្រពន្ធនិយាយ»អត់ទេ លោកគ្រូថាចឹងខុស តំបន់ហូបគ្រប់គ្រាន់ជាងគេមានតំបន់៥និងតំបន់៣តែតំបន់៥ហូបគ្រប់គ្រាន់ជាងគេ ព្រោះស្រូវធ្វើបានច្រើនជាងគេ ។

វណ្ណៈៈ តែតាមខ្ញុំដឹងតំបន់៥ធ្វើបានស្រូវច្រើន តែប្រជាជនខ្វះខាត តែតំបន់៣ប្រជាជនមានហូបគ្រប់គ្រាន់ ព្រោះខ្ញុំបានជួប តា ញ៉ឹកលី តា ញ៉ឹកលីហ្នឹងគាត់ក៏ជាខ្សែតា នួន ជាដែរ ហើយតាញ៉ឹកលីហ្នឹងគាត់និយាយថាបានជួយប្រជាជន កាលហ្នឹងអង្គការឲ្យគណៈឃុំនីមួយៗរាយការណ៍ជូនថ្នាក់លើ ចឹងនៅពេលស្រូវធ្វើបាន១០តោន ចឹងគាត់រាយការណ៍ទៅតែ៧តោនទេ ចឹងគាត់លាក់បាន៣តោន អង្គការទុកឲ្យ២តោនវិញទៀតចឹងបាន៥តោន ចឹងទៅប្រជាជនមានហូបគ្រប់គ្រាន់ ចឹងគាត់និយាយចឹងហើយខ្ញុំមិនបានជឿគាត់ទាំងស្រុងទេ ខ្ញុំទៅសួរប្រជាជនដែលធ្លាប់រស់នៅក្នុងតំបន់គាត់ទៀត ចឹងទៅប្រជាជនថា មានរបបហូបគ្រប់គ្រាន់មែនឥឡូវនេះអ្នកភូមិហៅគាត់ថា ពុកលី កាលហ្នឹងតំបន់៤មានសម្លាប់ច្រើន កាលហ្នឹងគេសម្លាប់ប្ដីនៅតំបន់៤ តែប្រពន្ធរត់មកដល់តំបន់៣ ប្រពន្ធរត់មកចូលតំបន់៣ហើយឈ្លបមកដល់ចឹង គាត់ថាមនុស្សហ្នឹងរត់ចូលដីគាត់ហើយគាត់ដេញឈ្លបឲ្យទៅវិញទៀត គាត់ថាមនុស្សនេះបានចូលដល់តំបន់៣ហើយចឹងមិនអាចយកទៅវិញបានទេ ហើយឈ្លបក៏មិនហ៊ានជាមួយគាត់ទៀត ។

ជុនៈ ចាស«ប្រពន្ធនិយាយ» ។

វណ្ណៈ គាត់នៅរាល់ថ្ងៃនេះ គាត់អាយុ៨០ជាងហើយ ។

ជុន ៈ ចឹងគាត់ធ្វើល្អកាលសម័យហ្នឹងនោះ ។

វណ្ណៈៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំឆ្ងល់ដែលខ្ញុំឆ្ងល់ថាចេះខ្ញុំនៅកន្លែងឃ្លាំងចឹងសម្ភារដឹកឲ្យប្រជាជនគ្មានសម្រាកទេលោកគ្រូ ជួនណារថភ្លើងដឹកចេញពីភ្នំពេញជួនណាលីចេញមួយអាទិត្យមិនអស់ទេ ដឹកចេញត្រីរាប់ពាន់តោន ហេតុអីបានជាប្រជាជនអត់ហូបខ្ញុំ ឆ្ងល់មែនទែនណាស់ ដូចជាតាប៉ុល ពតគាត់ចង់ចុះមកចឹង គាត់ចុះតាមរយៈឃ្លាំងចឹង ឃ្លាំងគេមានឡាននោះ ។

វណ្ណៈ បាទ ។

ជុន ៈ ចាស«ប្រពន្ធនិយាយ»គាត់ឲ្យអ្នកដឹកជញ្ជូនហ្នឹងដាក់ឥវ៉ាន់នៅកន្លែងណាខ្លះច្រើនជាងគេ ឥឡូវជូនគាត់ទៅគាត់ទៅលោកគ្រូមែន តាមខ្ញុំមើលទៅមិនមែនមកពីតា ប៉ុល ពតទេ ដូចថាឥឡូវចូលដល់សហករណ៍លោកគ្រូវឯងហើយ លោកគ្រូឯងដឹងថាអ្នកធំមកហើយ គេគេតាមហើយណាស់ ។

វណ្ណៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»បាយម្ហូបពេញៗផ្ទះតាម សហករណ៍សាច់ជ្រូកភ្លូរ កន្លែងគេធ្វើម្ហូបពេញៗកាធុនដល់ដើរទស្សនៈកិច្ចទៅប្រជាជនខ្ញុំមានហូបគ្រប់គ្រាន់ ហើយហ្នឹងខ្ញុំគិតខ្លួនខ្ញុំម្យ៉ាងទេលោកគ្រូ ។

វណ្ណៈៈ បាទ ។

ជុន ៈ និយាយពីត្រីក្នុងមួយសហករណ៍មួយអាទិត្យ២៥តោន ត្រីងៀត ប្រហុកមិនគិត ត្រីឆ្អើរមិនគិតចុះហេតុអីបានជាប្រជាជនអត់ ។

វណ្ណៈៈ ខ្ញុំក៏មិនដឹងដែរ ។

ជុន ៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំកើតជាឆ្ងល់ ខ្ញុំចេះតែឆ្ងល់ខ្លួនខ្ញុំមិនដែលបានសម្រាក់ថា៧យប់៧ថ្ងៃ ដូចថាឥឡូវប្រជាជនមិនមានទេ តាមសហករណ៍មួយទៅសហករណ៍មួយតំបន់៣ តំបន់៥តំបន់៧ខាងណាអត់ពួកខ្ញុំទៅហ្នឹងហើយពួកខ្ញុំមានតែ១៥នាក់ទេ ។

វណ្ណៈៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ ១៥នាក់ហ្នឹងមូលដ្ឋានមកពីតាកែវមកលោកគ្រូ ។

វណ្ណៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ» អ្នកនៅជាមួយនោះហ្នឹងគេហៅអ្នក១៧មេសានោះ ។

វណ្ណៈ   បាទ ។

ជុន ៖   ចាស «ប្រពន្ធនិយាយ» នោះ៣០០នាក់ ។

វណ្ណៈ៖   បាទ ។

ជុនៈ   ចាស «ប្រពន្ធនិយាយ» នៅជាមួយពួកខ្ញុំមិនដែលមានផលរមាស់អីទេ   ថាពួកខ្ញុំមានហូបពួកគាត់អត់ហូប  គឺអត់មានទេហូបជាមួយគ្នាកម្មករ៣០០សុទ្ធតែពូៗពួកខ្ញុំ១៥នាក់សុទ្ធតែស្រីៗហ្នឹង ។

វណ្ណៈ   បាទ ។

ជុន ៖   ចូលហូបជាមួយគ្នាទាំងអស់អត់មានបញ្ហាអីទេ   ហើយគាត់ថាយកតាមសហករណ៍ក្នុងមួយឡានមានអ្នកមាន១៥នាក់សម្រាប់លើកប្រហុកលើកត្រីអីចេញណាស់ ។

វណ្ណៈ   បាទ ។

ជុនៈ   ចាស «ប្រពន្ធនិយាយ» មានពួកខ្ញុំតែពីនារទេក្នុងមួយឡានហ្នឹង ។

វណ្ណៈ   បាទ ។

ជុនៈ   ចាស «ប្រពន្ធនិយាយ»   តែខ្ញុំឆ្ងល់ថាពួកខ្ញុំដឹកចង់ផាប់ខ្លួនហើយហេតុអីបានជាប្រជាជនអត់មានហូបខ្ញុំឆ្ងល់ត្រង់ហ្នឹងទេ ។

វណ្ណៈ៖   ចឹងដឹកដល់ហើយមិនដឹងជាគេយកទៅណា?

ជុន ៖   ចាស!មិនដឹងជាគេយកទៅណា  អ្នកធ្វើអង្ករនៅតាមរោងម៉ាស៊ីនហ្នឹងយ៉ាប់ជាងពួកខ្ញុំទៀត  គ្ន  គ្មានបានដេកទេ  ហក់សហករណ៍នេះអត់មានអង្ករទេ  ខ្ញុំសំរុកមួយយប់ទាល់ភ្លឺ  ដូរ  វេនគ្នាដល់ណាស់ពេកពួករោងម៉ាស៊ីនយ៉ាប់ខ្លាំងណាស់  កាលសម័យហ្នឹងហើយពួកខ្ញុំនេះ  និយាយត្រីយកពីទន្លេសាបមកចូលឃ្លាំងឃ្លាំងបញ្ចេញទៅក្រៅហើយនៅតែប្រជាជនអត់ហូបខ្ញុំដូចជាឆ្ងល់ ។

វណ្ណៈ៖   ចុះបើគេមិនឲ្យហូប?

ជុនៈ   ចាស «ប្រពន្ធនិយាយ» ហើយស្រែបើថាស្ករត្នោតតាមសហករណ៍អត់មានស្ករកាដុងចេះទេ   មានតែផុងសាំង ។

វណ្ណៈ   បាទ ។

ជុន ៖   ចាស «ប្រពន្ធនិយាយ» ដូចថាសហករណ៍គេកំម៉ុង១០ពុយលើកដាក់ឡានព្រឹបៗ   ដូចជា១០ពុយកំណត់ប៉ុន្មានដូចជាពីរអាទិត្យអី  ដឹកទៅទៀតហើយមិនដឹងជាយកទៅចោលនៅណាអស់ប្អូនដប់ម្តៃពុយអី ។

វណ្ណៈ៖   ចឹងកាលឆ្នាំ៧៨ហ្នឹងមកពីតាកែវតែ៧នាក់ទេ?

ជុន ៖   ចាស «ប្រពន្ធនិយាយ» ខ្ញុំមកគ្នាច្រើនតែបែកតាមកន្លែង ។

វណ្ណៈ៖ ចឹងកាលនៅតាកែវកាលឆ្នាំ៧៧ហ្នឹងពេលគេចាប់តា រស់ ញ៉ឹមទៅមានពីណាមកកាន់កាប់នៅខេត្តហ្នឹង?

ជុន ៖ ចាស«ប្រពន្ធនិយាយ» តា ញ៉ឹមចាប់នៅបាត់ដំបងនៅឆ្នាំ៧៧ ។

វណ្ណៈ បាទ!ចាប់នៅបាត់ដំបងកាលឆ្នាំ៧៧ហ្នឹង?

ជុនៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំអត់ដឹងដែរ ។

វណ្ណៈ៖ ចឹងមានអ្នកមកជំនួសតា ញ៉ឹមទេ?

ជុន ៖ ចាស«ប្រពន្ធនិយាយ» ខ្ញុំមិនបានដឹងគេចាប់ផង ព្រោះការពីនេះហ្នឹងខ្ញុំនៅកន្លែងហ្នឹងគេឲ្យប្រមូលសម្ភារហើយណាស់ ។

វណ្ណៈ៖ បាទ ។

ជុន ៖ ចាស«ប្រពន្ធនិយាយ» ឥឡូវគេថាកម្មកព្វកឃ្លាំងហ្នឹងឲ្យទៅយកមាសកន្លែងតា ញ៉ឹម ខ្ញុំវាមិនបានចាប់អារម្មណ៍ថាគេចាប់តាញ៉ឹមទៅណាខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ» ព្រោះនៅកន្លែងហ្នឹងគ្រាន់តែដឹងថា ដូចថាកំលាំងយើងគេឲ្យទៅយកមាសនាំគ្នាទៅយកមាសកន្លែងគាត់មកខ្ញុំគ្រាន់ដឹងថាប្រពន្ធគាត់ច្រើនប៉ុណ្ណឹងឯង ។

វណ្ណៈ៖ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»នាំគ្នាទៅនិយាយលេងទៅសួរនាំអីហ្នឹងដឹងតែប៉ុណ្ណឹង ។

វណ្ណៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»ត្រង់គេចាប់គាត់យកទៅណាខ្ញុំមិនបានដឹងទេ ។

វណ្ណៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»គ្រាន់ថាឥឡូវឲ្យទៅប្រមូលសម្ភារពីកន្លែងគាត់ហ្នឹង ។

វណ្ណៈ បាទ ។

ជុន ៖ ចាស«ប្រពន្ធនិយាយ» កាលហ្នឹងប្រមូលមាសបាន៧កំណាត់បារប្រមូលកន្លែងតា ញ៉ឹម យកទៅដាក់ក្នុងឃ្លាំង ។

វណ្ណៈ ចឹងមានច្រើន?

ជុនៈ ចាស«ប្រពន្ធនិយាយ»យកមកដាក់ក្នុងឃ្លាំងបាត់ដំបងហ្នឹងយកពីគាត់៧កំណាត់បារ ។

វណ្ណៈ៖ យកពីផ្ទះគាត់ឬមួយយកពីណា?

ជុន ៖ ចាស«ប្រពន្ធនិយាយ» យកពីកន្លែងផ្ទះគាត់ហ្នឹង ។

វណ្ណៈ៖ ៧កំណាត់បារអីគេ?

ជុន ៈ ចាស «ប្រពន្ធនិយាយ» បាវពោះខ្យងហ្នឹងបាវក្រចៅហ្នឹង តែពួកខ្ញុំគ្រាន់តែយករបស់មកដល់ចឹង យកទៅឲ្យកន្លែងរោងជាងគេធ្វើជាចបកាប់ធ្វើជាដុំឥដ្ឋ យកមាសណាស់លោកគ្រូយកមាសហ្នឹង ធ្វើផ្លែចបកាប់ ធ្វើចបកាប់ក៏មានដុំឥដ្ឋក៏មានដែរ ចាក់ពុម្ពធ្វើហើយដាក់ក្នុងឡាំងខ្ទមបេឡដិត មិនដឹងជាយកទៅណាទេ ខ្ញុំមិនបានដឹងទៀតយកទៅទុកណាខ្ញុំក៏មិនបានដឹងដែរ ។

វណ្ណៈ៖ ខ្ញុំឮគេនិយាយដែលថាធ្វើចបកាប់ហ្នឹង?

ជុន ៈ ចាស «ប្រពន្ធនិយាយ» បើខ្ញុំធ្វើចបកាប់នៅកន្លែងរោងសកលហ្នឹងតែម្ដងហើយ លោកគ្រូមានស្គាល់សកលហ្នឹងទេ ។

វណ្ណៈ អត់ផង ។

ជុនៈ ចាស «ប្រពន្ធនិយាយ» សកលនៅបាត់ដំបងនេះ កន្លែងហ្នឹងជាកន្លែងទទួលភ្ញៀវ ។

វណ្ណៈ ចឹងធ្វើចបកាប់និងធ្វើអីទៀត?

ជុនៈ ចាស «ប្រពន្ធនិយាយ» ធ្វើជាពុម្ពដិតដ្ឋ ធ្វើដុំៗដូចជាឥដ្ឋចឹងទៅណាស់ ។

វណ្ណៈ៖ មីងឮគេនិយាយទេឬបានឃើញផ្ទាល់?

ជុន ៈ ចាស «ប្រពន្ធនិយាយ» ខ្ញុំជាអ្នកដើរប្រមូលមាសយកមកដាក់កន្លែងរោងជាង ជាងធ្វើហើយដាក់ឡាំងខ្ទមបេមិនដឹងជា យកទៅណាទៀតខ្ញុំមិនដឹង ខ្ញុំដឹងតែត្រឹមហ្នឹងឯងភារកិច្ចចប់តែត្រឹមហ្នឹង មានតៗទៀតខ្ញុំម៉េចដឹង ។

វណ្ណៈ ចឹងមីងមិនដឹងជាយកទៅណាទេ?

ជុនៈ ចាស «ប្រពន្ធនិយាយ» ខ្ញុំមិនបានដឹងយកទៅណាខ្ញុំដឹងតែប្រមូលមកចូលរោងជាងហ្នឹង រោងជាងធ្វើហើយមិនដឹងជាទៅណា ។

វណ្ណៈ មាសកាលជំនាន់ហ្នឹងនិយាយអីច្រើនណាស់?

ជុនៈ ចាស «ប្រពន្ធនិយាយ» ។

វណ្ណៈ ចឹងកាលចូលមកហ្នឹងនៅភ្នំពេញមានមាសរាប់តោននោះមិនពីណាយកទៅណាទេ?

ជុនៈ ចាស «ប្រពន្ធនិយាយ» យើងមិនដឹងពីជាយកទៅណា ។

វណ្ណៈ កាលហ្នឹងខ្មែរក្រហមប្រមូលបាន?

ជុនៈ មិនដឹងពីណាយកទៅណាអស់ ។

វណ្ណៈ យើងមិនដឹងពីណាយកទៅណាបើយើងមិនដឹងដែរ?

ជុនៈ យួនចូលមកយកអស់ដឹងចុះ ។

វណ្ណៈ យើងមិនដឹងដែលបើយើងមិនបានឃើញ មាសសូម្បីយកទៅណាក៏យើងមិនដឹងដែរ ដាក់ទៅចិនឬទៅណាក៏យើងមិនដឹង?

ជុនៈ ចាស«ប្រពន្ធនិយាយ»ព្រោះវាមានអ្នកទទួលខុសត្រូវមួយដំណាក់ៗចឹង ដូចជាគ្រាន់តែប្រមូលឧបករណ៍ពីកន្លែងមកចឹង គេថាឥឡូវទៅប្រមូលមកសម្រាប់ចូលឃ្លាំង ឃ្លាំងយកមកសម្រាប់ចូលទៅដាង ហើយដាងគេមិនដឹងប្រមូលទៅណាទៀត ដាងគេបញ្ចេញទៅណាយើងមិនដឹងទេ ។

វណ្ណៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»ហើយវាមិនបានដឹងត្រង់ហ្នឹង ។

វណ្ណៈ៖ ចឹងនៅខេត្តបាត់ដំបងហ្នឹងមានពីតំបន់១រហូតដល់តំបន់៧មែនទេ?

ជុន ៖ ចាស«ប្រពន្ធនិយាយ» ។

វណ្ណៈ៖ ចឹងអ្នកមកពីតាកែវហ្នឹង បែកចែកទៅតាមតំបន់មួយៗទៅ?

ជុន ៖ ចាស«ប្រពន្ធនិយាយ»!កាលពួកខ្ញុំមកហ្នឹងមាន៣០០នាក់ជានារីស្រែអំបិល ។

វណ្ណៈ៖ ចឹងយកពីស្រែអំបិលមកវិញទេ?

ជុន ៖ ចាស«ប្រពន្ធនិយាយ»ចាស!ខ្ញុំចប់ពីយោធាមក ខ្ញុំមកនៅស្រែអំបិល មើល៧៥គេដកពួកខ្ញុំពីភ្នំពេញមកនៅស្រែអំបិលដល់៧៧គេដកពីស្រែអំបិលមកឲ្យមកនៅបាត់ដំបង កាលហ្នឹងគេដកមកមានគ្នា៣០០នាក់ ណាពូ ពេលមកដល់គេបែកចែកទៅតាមសហករណ៍ ចឹងពួកខ្ញុំនៅសល់តែគ្នា១៥នាក់ហ្នឹងមកនៅឃ្លាំងហ្នឹងតែម្ដង ។

វណ្ណៈ៖ បាទ ។

ជុន ៖ ចាស«ប្រពន្ធនិយាយ»គេចែកគ្នាចឹងទៅណាស់ ចឹងរហូតមករត់យួនតែម្ដងរត់ពីបាត់ដំបងចឹងមកដល់៧៩រត់យួន ។

វណ្ណៈ៖ ចឹងរត់បែកបងប្អូនចឹងទៅ?

ជុន ៖ ចាស«ប្រពន្ធនិយាយ»ខ្ញុំរត់ចោលម៉ែខ្ញុំតាំងពី៧៣មកម្លេះ តាំងពីសម័យលន់ នល់ ។

វណ្ណៈ៖ ចឹងកាលស្រុកកំណើតនៅណាដែរ ភូមិឃុំអី?

ជុន ៖ ចាស«ប្រពន្ធនិយាយ»ខ្ញុំនៅភូមិខ្វែងកោង ឃុំញ៉ែងញ៉ង ស្រុក១០៥ ឥឡូវខេត្តតាកែវ ។

វណ្ណៈ៖ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»កាលពីមុនគេហៅ១០៥ ។

វណ្ណៈ ស្រុក១០៥ហ្នឹងសព្វថ្ងៃគេហៅស្រុកអី?

ជុនៈ ចាស«ប្រពន្ធនិយាយ»សព្វថ្ងៃខេត្តតាកែវ ។

វណ្ណៈ តែឥឡូវគេហៅស្រុកអី?

ជុនៈ ចាស«ប្រពន្ធនិយាយ»ឥឡូវគេហៅស្រុកត្រាំកក់ គេដូរស់ប្តូរចឹងឯង ។

វណ្ណៈ បាទ ។

ជុនៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំចេញពីម៉ែឪខ្ញុំតាំងពីអាយុ១៨ឆ្នាំ ចេញពីម៉ែឪខ្ញុំ ។

វណ្ណៈ បាទ ។

ជុន ៈ ចាស«ប្រពន្ធនិយាយ»មុនដំបូងខ្ញុំនៅខាងសិល្បៈ សិល្បៈតាមភូមិរហូតមកស្រុក ក្រោយមកទៀតគេរើសនារីយោធា ដល់ហើយខ្ញុំសុំគេចូលយោធា ។

វណ្ណៈ ចឹងចូលយោធាទៀតទៅ?

ជុនៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំសុំគេចូលយោធា ។

វណ្ណៈៈ ចឹងចេះបាញ់ទេ?

ជុន ៈ ចាស!ចេះបាញ់ តែឲ្យហំហានទៅរកគេតែម្ដងអត់ទេ បានតែម៉ាដោះស្រាយខ្លួន ដល់ពេលយើងកុនអាចដោះស្រាយខ្លួនបានតែប៉ុណ្ណោះ ឲ្យទៅសម្លាប់គេតែម្ដងអត់ទេ ។

វណ្ណៈៈ បាទ ។

ជុន ៈ ចាស«ប្រពន្ធនិយាយ»ដល់មករហូតខ្ញុំមកនៅត្រាំខ្នារ ដល់មកវៃភ្នំពេញនេះពួកខ្ញុំគ្រាន់តែបានមកចូលបៀតទេ យើងនារីគេអត់មានឲ្យយើងសម្រុកទៅមុខទេ គេឲ្យយើងតាមស្នែងនិងកាន់ខ្សែទូរស័ព្ទតែប៉ុណ្ណឹង ។

វណ្ណៈៈ ចឹងនៅពេលរត់មកដល់ព្រំដែនហើយឆ្នាំ៨០-៨១-៨២ហ្នឹងអត់មានបានទៅរកស្រុកកំណើតទេ?

ជុន ៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំអត់ទេ ។

វណ្ណៈៈ ចឹងឆ្នាំណាបានត្រឡប់ទៅលេងផ្ទះនៅស្រុកកំណើត?

ជុន ៈ ចាស«ប្រពន្ធនិយាយ»ផ្ដាច់ខ្លួនហើយនេះបានប៉ុន្មានឆ្នាំបានហ៊ានទៅលេងទៅលេងចង់ខ្លាចទៀតមិនហ៊ានទៅទៀត ។

វណ្ណៈៈ ហេតុអីបានខ្លាច?

ជុន ៈ ចុះឯងនៅនេះយូរគេនៅនោះមិនទុកចិត្ត នៅខ្លាចនៅឡើយទេទាល់តែផ្ដាច់ខ្លួនមែនទែន ។

វណ្ណៈៈ ចឹងមីងបានទៅលេងបានប៉ុន្មានដង?

ជុន ៈ ចាស«ប្រពន្ធនិយាយ»ខ្ញុំបានទៅលេងម្ដងជុំប្ដីប្រពន្ធហ្នឹង ដល់នេះខ្ញុំយកម៉ែខ្ញុំមកនៅហ្នឹង ព្រោះឪពុកខ្ញុំស្លាប់ទៅនៅម៉ែ ដូចជាខាងពុកខ្ញុំនោះស្លាប់អស់ហើយ ។

វណ្ណៈៈ ចឹងពូទៅលេងស្រុកបានប៉ុន្មានដង?

ជុន ៈ បានទៅលេងពីរទៅបីដងដែលហ្នឹង ខ្ញុំនៅជិតកំពង់ស្ពឺនេះ ។ ប្រពន្ធនិយាយ« ខ្ញុំនៅជិតព្រំដែនយួននោះ នៅភ្នំដិននោះនៅភ្នំក្រពើជាប់ភ្នំដិន ។

វណ្ណៈៈ ចឹងមិនមែនត្រាំកក់ទេ?

ជុន ៖ ចាស«ប្រពន្ធនិយាយ»ត្រាំកក់ហ្នឹងគ្រាន់តែស្រុកកំណើតខ្ញុំទេ ដល់ពេលម៉ែខ្ញុំគាត់រត់សម័យនេះចឹងគេឲ្យម៉ែខ្ញុំទៅនៅភ្នំដិនភ្នំក្រពើនោះ ភ្នំក្រពើគីរីវង្សដល់ខ្ញុំទៅលេងទៅលេងហ្នឹង ។

វណ្ណៈ៖ ចឹងមិនលែងចង់ទៅលេងស្រុកកំណើតទៀតហើយ?

ជុន ៖ ខ្ញុំអត់ស្គាល់ទេ ខ្ញុំអស់បងប្អូនហើយ ។

វណ្ណៈ៖ ចឹងពូអត់មានចង់ទៅនៅកំពង់ស្ពឺទេ?

ជុន ៖ បើនៅក៏គ្មានដីដែរ បើទៅនៅបានអីធ្វើស្រែ ។

វណៈ ចឹងមុនរបរយើងហ្នឹងហើយ?

ជុនៈ បាទ ។

វណ្ណៈ កូនចៅនៅទីនេះហើយ?

ជុនៈ បាទ! ឥឡូវមានដីចំការនៅនេះកូនចៅនៅទីនេះហើយ កូនខ្ញុំអាបងគេជិត ៣០ឆ្នាំហើយ ស្រុកកំណើតវានៅទីនេះឯង ។

វណ្ណៈ៖ ចឹងចាំថ្ងៃណាមានលុយច្រើននាំគ្នាទៅលេងស្រុកម្តងទៅ?

ជុន ៖ ចាស«ប្រពន្ធនិយាយ»ទៅលេងមិនដឹងជាទៅលេងឯណាបើប្អូនៗខ្ញុំមកនៅនេះដែរ នៅតែមីងមាខ្ញុំមិនសូវស្គាល់ទេ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរពូវិញម្តងទៀត កាលនៅហ្នឹងពូនៅឆ្នាំ១៩៨៥ពូថាបានមកនៅម៉ាឡៃ?

ជុន ៖ បាទ ។

វណ្ណៈ៖ ចឹងម៉ាឡៃហ្នឹងគេចាប់ហៅតាំងពីពេលណាមក?

ជុន ៖ តាំងពីខ្ញុំចូលមកគេហៅតែម៉ាឡៃហ្នឹងរហូត ។

វណ្ណៈ ខ្លះគេហៅថាភូមិដូងៗ?

ជុនៈ ហ្នឹងគេហៅភូមិដូងដែរ ម៉ាឡៃហ្នឹងគួបនិងស៊ីសាផុនខាងត្បូងហ្នឹងតែម្តង ។

វណ្ណៈ៖ ចឹងពេលដែលកើតចេញជាស្រុកម៉ាឡៃចឹងកើតនៅពេលណា?

ជុន ៖ កើតស្រុកម៉ាឡៃកើតនៅពេលផ្តាច់ខ្លួនហ្នឹងតែម្តង ។

វណ្ណៈ៖ ចឹងកាលមុនមានភ្នំម៉ាឡៃនៅជិតហ្នឹងបានជាគេហៅភ្នំម៉ាឡៃ?

ជុន ៖ មានភ្នំម៉ាឡៃហ្នឹងដឹងនៅណា ។

វណ្ណៈ៖ ចឹងនៅម៉ាឡៃហ្នឹងកាលឆ្នាំ៨៥ហ្នឹងនៅមានព្រៃនៅឡើយទេ?

ជុន ៖ និយាយពីព្រៃហ្នឹងគ្មានមើលពន្លឺថ្ងៃឃើញទេ ។

វណ្ណៈ៖ ចឹងនៅខាងចក្រីនិងត្រាងនោះមានព្រៃទេ?

ជុន ៖ មានព្រៃដូចតែគ្នា ។

វណ្ណៈ ចុះឥឡូវវាលទេ?

ជុន ៖ វាលអស់ហើយ វាលលើសនៅទីនេះទៀត ។

វណ្ណៈ ចឹងកាលនៅចក្រីហ្នឹងនៅក្នុងព្រៃសុទ្ធ?

ជុន ៖ នៅក្នុងព្រៃសុទ្ធ ។

វណ្ណៈ ចឹងតាំងពីប្រពន្ធកូននៅក្នុងព្រៃសុទ្ធ?

ជុន ៖ នៅក្នុងព្រៃសុទ្ធ ។

វណ្ណៈ ចឹងកាលហ្នឹងមានដើមឈើធំៗទេ?

ជុន ៖ មានដើមឈើធំៗ កាលហ្នឹងមានដើមប៉េងធំៗណាស់ បើគុម្ពឫស្សីវិញហ្នឹងដើរមួយតឹឡូមិនទាន់ផុតគុម្ពឫស្សីផង ។

វណ្ណៈ ចឹងពូស្រម៉ៃមើលថា ឈើទាំងហ្នឹងអស់នៅពេលណាអស់មុនហ្នឹងឬមួយអស់នៅពេលសមាហរណកម្មហើយ?

ជុន ៖ អស់ក្រោយពេលយួនដកចេញហ្នឹង អស់តាំងពីពេលហ្នឹង ។

វណ្ណៈ យួនដកចេញនៅឆ្នាំ៨០ជាងហ្នឹង?

ជុន ៖ ហ្នឹងហើយដកចេញបានសំរុះសម្រួលគ្នាតែមិនផ្តាច់ខ្លួនទេ តែកាលហ្នឹងអារលក់ឲ្យថៃតាំងពីពេលហ្នឹងមក ។

វណ្ណៈ ចឹងអារលក់ឲ្យថៃដើម្បីដោះដូរសម្ភារជាមួយថៃ?

ជុនៈ បាទ ។

វណ្ណៈ ចឹងពូថានៅឆ្នាំ៨៧យួនដកទ័ពចេញហ្នឹង ថាចិនលែងផ្តល់ជំនួនឲ្យខាងខ្មែរក្រហមហើយមែនទេ?

ជុន ៖ ឈប់ហើយ ។

វណ្ណៈ ចឹងខាងខ្មែរក្រហមដោះស្រាយខ្លួនឯង?

ជុន ៖ ខ្លួនឯង ។

វណ្ណៈ ចឹងអ្នកណានៅកន្លែងត្បូងជីកត្បូងទៅអ្នកណានៅកន្លែងមានឈើកាប់ឈើទៅ?

ជុន ៖ ហ្នឹងហើយ ។

វណ្ណៈ ចឹងអស់ដោយសារចឹងទេ?

ជុនៈ បាទ ។

វណ្ណៈ ដល់ក្រោយមកទៀតចឹងនៅពេលផ្តាច់ខ្លួនហើយប្រជាជនកាប់វាលឈើយកដីធ្វើចំការ?

ជុន ៖ ហ្នឹងហើយប្រជាជនកាប់យកដីធ្វើចំការ ។

វណ្ណៈ ចឹងមានគ្រោះថ្នាក់ដោយសារមីនទេ?

ជុន ៖ មានអ្នកគ្រោះថ្នាក់ដោយសារមីន ចុះអត់មានដីចេះតែកាប់ទៅ ។

វណ្ណៈ ចឹងកាលហ្នឹងសម្តេចមកផ្ញើសារតាំងនៅតំបន់ហ្នឹងពូមកមិនទាន់ទេ?

ជុន ៖ ខ្ញុំមកមិនទាន់ទេ គ្រាន់ឃើញគេមកតែដឹងថាសម្តេចមកអត់មានពីណាទៅ ទៅណាយោធាត្រូវការពារនៅខាងនេះ ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅចក្រីនៅឡើយ?

ជុន ៖ នៅចក្រីនៅឡើយ ។

វណ្ណៈ តែសម្តេចមកសារតាំងនៅកន្លែងនេះ?

ជុន ៖ ហ្នឹងហើយ សម្តេចសីហមុនីបាននៅនេះ មកហាត់សិល្បៈចេញចូល ។

វណ្ណៈ ចឹងកាលហ្នឹងមានអ្នកកាសែតមកច្រើនទេ មានកាសែតជប៉ុនបារាំងអី?

ជុន ៖ មានមកចំរុះ ។

វណ្ណៈ តែពូមិនបានឃើញទេ?

ជុន ៖ បាទ!មិនបានឃើញទេ ។

វណ្ណៈ ចឹងតាមខ្ញុំដឹងសម្តេចមកប្រហែលជាបីដងដែរ កាលឆ្នាំ៨១-៨២-៨៣ហ្នឹង?

ជុន ៖ មិនដឹងជាមកប៉ុន្មានដងខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ កាលហ្នឹងមកជាមួយថៃមានគណៈប្រតិភូថៃអីចឹង?

ជុនៈ បាទ!ពួកខ្ញុំនៅនេះតាំងពី៨៥ ។

វណ្ណៈ តែនៅមានព្រៃណែនតែនគាប់ចឹង?

ជុនៈ នៅព្រៃណែនចឹង ខ្ញុំមកនេះនៅព្រៃ ។

វណ្ណៈ ចឹងកាលហ្នឹងមានទាហានខាងក្នុងមានវៃមកហើយសុំចុះចូលជាមួយទាហានខ្មែរក្រហមមានទេ?

ជុន ៖ មាន តែខ្លះចូលមកចឹងមក តែចូលមកអត់សូវរៀនសូត្រហើយ នៅខ្លះហ្នឹងទៅខ្លះទៅវិញក៏ទៅៗ ខ្លះចង់ទៅម៉ែឪគេលែងទៅវិញទៅ ខ្លះចង់នៅយកប្រពន្ធកូននៅហ្នឹងក៏នៅទៅ ។

វណ្ណៈ ចឹងនៅតំបន់ម៉ាឡៃកាលជំនាន់ហ្នឹងមានពុថាចង់ប្រមូលទ្រព្យសម្បត្តិប្រជាជនមាន អាត្រាក់ទ័រមានម៉ូតូអីដាក់រួមចឹងមែន?

ជុន ៖ មានមែនកាលហ្នឹង កាលហ្នឹង តា សុន សេននោះ ។

វណ្ណៈ តា សុន សេន?

ជុនៈ តា សុន សេន ហៅតាខៀននោះ មិនមែនខៀវ សំផនទេ តា ខៀវហៅសុន សេន កាលហ្នឹងប្រមូលគោដាក់រួមហើយ លោក គ្រូមានឃើញនិម្មិត្តរូបគោហ្នឹង ដល់ប្រជាជនបាស់

បោលទៅហ្នឹងទុកឲ្យកូនចៅមើល តែកាលហ្នឹងមិនទាន់បានប្រមូលទេ គ្រាន់ជាគ្រោងការណ៍ទេ ឃ្លានេះប្រពន្ធគាត់និយាយលាយ ។

វណ្ណៈ ចឹងកន្លែងវង្វង់មូលហ្នឹងជានិម្មិត្តសញ្ញាប្រមូល?

ជុន ៖ ហ្នឹងហើយ ប្រមូលព្រោះកាលហ្នឹងនរណាមានគោមានអាត្រាក់មានឡានដកចេញទាំងអស់ ។

វណ្ណៈ តែមិនទាន់ដកកើតទេ ថាមានប្រជាជនប្រត្តិកម្ម?

ជុន ៖ កាលហ្នឹងដកអស់ខ្លះហើយបានប្រជាជនបាតុកម្មហ្នឹងដកអស់ហ្នឹងហើយ ។

វណ្ណៈ ចឹងដកបានហើយ?

ជុនៈ ដកបានហើយ ។

វណ្ណៈ ដកបានដាក់រួមហើយ?

ជុនៈ ដកដាក់រួមអស់ខ្លះហើយអាត្រាក់យកទៅអស់រលីង ។

វណ្ណៈ យកទៅណាទៅ?

ជុន ៖ យកទៅដឹកជញ្ជូនយកទៅបំរើសមរភូមិដឹកទឹកអីចោលរគាត់រគាយអស់ ។

វណ្ណៈ កាលហ្នឹងប្រហែលជាឆ្នាំណា?

ជុនៈ យី!ដូចថាឆ្នាំ៨០ជាង ។

វណ្ណៈ ខ្ញុំឮការថា៩០ជាងហើយមែនទេ?

ជុនៈ ៩០ហើយមិនមែន៨០ទេ៩០ ។

វណ្ណៈ ប្រហែលជា៩០ប៉ុន្មាន?

ជុន ៖ មើល៩៦យើងផ្ដាច់ខ្លួន ។

វណ្ណៈ ៩៦ផ្ដាច់ខ្លួន?

ជុនៈ ៩៦ចាប់ពីលើបីឆ្នាំមក ។

វណ្ណៈ ចឹង?

ជុនៈ ហ្នឹងហើយប្រហែលជាឆ្នាំ៩២-៩៣ ។

វណ្ណៈ ចឹង៩២-៩៣ប្រមូលដាក់រួមបាន?

ជុនៈ ហ្នឹងហើយ តា ខៀវប្រមូលអស់ហើយយក គោកាប់យកទៅបំរើសមរភូមិយោធាហ្នឹងហើយ បានរីកវត្ថាខ្លាំងណាស់ កាលហ្នឹងគេថាមនុស្សរាប់រយរាប់ម៉ឺនមកបាក់អា មនុស្សម្នាក់ពីរនាក់ចឹង ផ្ដាច់ខ្លួនបណ្ដោយកុំអីមិនទាន់ងាយចប់ទេ ។

វណ្ណៈ ចឹងកាលហ្នឹងយករបស់បានមួយចំនួនហើយ?

ជុន ៖ កាលហ្នឹងបានឡាននិងអាត្រាក់ កាលហ្នឹងឡានយកទៅអស់ហើយ នៅមានតែនការណ៍ដកដីដកគោទៀត ដល់ខ្លាំងមែនចង់ធ្វើបាយរួមទៀត ដូចថាអ្នកធ្វើស្រែចំការបានលុយដកឲ្យអស់ទុកឲ្យតែ៥០០០០សម្រាប់ចិញ្ចឹមគ្រួសារ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមានយកត្រាក់ទ័រគោមិនទាន់យកទេ?

ជុន ៖ គោយកខ្លះហើយ ។

វណ្ណៈ៖ ចឹងកាលហ្នឹងម៉ូតូ?

ជុន ៖ ម៉ូតូមិនទាន់មានទេ កាលសម័យហ្នឹង ។

វណ្ណៈ ចឹងមានយកឡានអាត្រាក់យកគោ?

ជុនៈ បាទ ។

វណ្ណៈ៖ ចឹងកាលហ្នឹងចង់បង្កើតសហករណ៍បាយរួម?

ជុន ៖ ហ្នឹងហើយចង់បង្កើតតែមិនដឹងថាចង់បង្កើតអីទេ ឮថាគេចង់បង្កើតជាបាយរួមតែប្រជាជនមិនព្រមកាលហ្នឹងមានប្រជាជនឯណាមានតែគ្រួសារយោធាហ្នឹង យកប្តី ទៅមុខ ប្រពន្ធនៅក្រោយនិយាយចេះស្រែចំការដែលធ្វើបានប៉ុន្មានត្រូវដកវិញទាំងអស់ កាលហ្នឹងមួយគ្រួសារឲ្យប៉ុន្មានរ៉ៃទេកាលហ្នឹង ។

វណ្ណៈ៖ ចឹងនៅពេលដែលប្រជាជនមិនព្រមហ្នឹងចឹងមិនបានបង្កើតជាសហករណ៍ទេ?

ជុន ៖ ហ្នឹងហើយមិនបានបង្កើតទេ ។

វណ្ណៈ៖ កាលហ្នឹងមានហៅប្រជាជនមកប្រជុំទេ?

ជុន ៖ អត់មានចាំប្រជុំអីទេ គ្រាន់តែមានប្រកាសចឹងបណ្តោយ ។

វណ្ណៈ៖ ចឹងប្រជាជនចេះតែឲ្យទៅដែរ?

ជុន ៖ ចុះគេមកមានអំណាច គេមកមានស្រួលបួលណា មកមានអាវុធមានកាំភ្លើងមានកងការពារ ។

វណ្ណៈ៖ ចឹងនៅពេលដែលគាត់ដកហើយចឹងទៅដល់ក្រោយមកមានរឿងអីបានជាគាត់ស្លាប់?

ជុន ៖ ក្រោយមកគាត់បាស់បោលនៅហ្នឹងខ្លាំងហើយចាប់បាននៅអន្លង់វែង នៅអន្លង់វែងដឹងថា តាខៀវហ្នឹងក្បត់ចាប់សម្លាប់ចោលហ្នឹងបណ្តោយ ។

វណ្ណៈ៖ ចឹងគេអត់មានសម្លាប់សុន សេននៅទីនេះទេ?

ជុន ៖ គេសម្លាប់នៅអន្លង់វែងខ្ញុំមិនសូវដឹងទេ នៅអន្លង់វែងហ្នឹងឮថាស្រុះស្រួលគ្នាវិញតា ខៀវហ្នឹងសុំមកនេះវិញ មកម៉ាឡៃវិញបានតា ប៉ុល ពតថា ចុះអ្នកឯងរត់ចេញពីម៉ាឡៃម៉េចបានចង់ទៅម៉ាឡៃវិញ ចឹងនៅពេលហ្នឹងហើយបាញ់សម្លាប់បណ្តោយទៅកងការពារប៉ុល ពតហ្នឹងបាញ់ចោលមួយពូជរឿងហ្នឹងចឹងឯងបានចឹង ពេលនៅនេះមែនអត់មានបាយទឹកមែនអត់បាយ ។

វណ្ណៈ  យ៉ាងម៉េចបានអត់?

ជុនៈ  មិនដឹងជាយ៉ាងម៉េចអង្ករជំនួយមកពេញឃ្លាំងតែអង្ករឲ្យទៅខាងមុខអត់មានឲ្យហូបគ្រប់គ្រាន់ ។

វណ្ណៈ  ចឹង?

ជុនៈ  តែកាលហ្នឹងមិនយូរទេ ប្រហែលជាប៉ុន្មានខែហ្នឹងឯង ។

វណ្ណៈ  បាទ ។

ជុនៈ  ធ្វើទុកគ្នាប៉ុន្មានខែ ខែវស្សាចឹងកំពង់តែវ៉ៃគ្នាជាប់ដៃជងឲ្យទៅមុខអត់មានគ្រាប់ផង ។

វណ្ណៈ៖  ចឹងសុន សេន គាត់កាច?

ជុន ៖  កាច គេថាសុន សេន ប្រពន្ធកាចជាងប្ដីទៀតចេះរឿងដឹកនាំបើប្រពន្ធប្រាប់ឲ្យសម្លាប់ គឺសម្លាប់ខ្ញុំឮគេថាចឹង ទោះបីកូនក្មេងក៏សម្លាប់ដែរគ្នាមិនដឹងអីសោះ ។

វណ្ណៈ៖  ចុះកាលហ្នឹងគាត់ប្រធានគុកទួលស្លែងទាំងមូល?

ជុន ៖  ដឹងម៉េចខ្ញុំមិនដឹងផង តែឮចេះទៀតខ្ញុំឮតាមគេទេ តែមែនឬមិនមែនមិនដឹងទេ ថាកាលតាខៀវ សំផនទៅចរចានៅទីក្រុងភ្នំពេញនោះឲ្យឈប់ គេថាហ៊ានទៅបែកក្បាលហើយមិនទៅក៏ត្រូវតែទៅ ដែលមិនដឹងធ្វើម៉េចឲ្យឆាប់ចប់ដល់ចប់វ៉ៃបែកក្បាលមែន ចុះហេតុអីបានជាគេវ៉ៃបែកក្បាល ចុះសុន សេនហ្នឹងចូលទៅភ្នំពេញដែលម៉េចបានជានៅផ្ទះថ្មធ្វើព្រងើយ ។

វណ្ណៈ  បាទ ។

ជុនៈ  តាមពិតទៅគេថាសុន សេន ហ្នឹងខ្សែជាមួយយួនស័ក្តិប៉ុន្មានផ្កាយប៉ុន្មាននោះ ផ្កាយ៥ខ្ញុំឮគេនិយាយទេ មិនដឹងជាមែនឬកទេខ្ញុំមិនដឹងដែលតែឮពួកគេយើងកូនទាហានចេះតែតាមគេទៅ ។

វណ្ណៈ៖  បាទ!ចឹងគេថាសុន សនទៅជួបជាមួយយួន?

ជុនៈ  គេទៅជួបជាមួយយួននៅផ្ទះថ្មអាំងហើយ ។

វណ្ណៈ៖  ចឹងកាលដែលទៅហ្នឹង ទៅជាមួយលោកខៀវ សំផនដែរ?

ជុន ៖  ទៅជាមួយខៀវ សំផនដែរ តែខៀវ សំផនបែកក្បាលឡើងរថក្រោះមកវិញមក តែសុន សេនមានបែកក្បាលអីនៅអង្គុយនៅផ្ទះថ្មហ្នឹង គេទុកផ្ទះថ្មមួយហ្នឹងរឿងហ្នឹងហើយបានជាខៀវ សំផនមកវិញស្រែថាឥឡូវខ្មែរវ៉ៃគ្នាម្ដងទៀតរៀបចំកំលាំង កាលហ្នឹងឲ្យពួកអ៊ុនតាក់ដក ជំនាន់អ៊ុនតាក់ចូល ឲ្យពួកអ៊ុនតាក់ចេញពីស្រុកខ្មែរឲ្យអស់រៀបចំវ៉ៃគ្នាមួយសារទៀត វ៉ៃគ្នារហូតដល់ឥឡូវមក តាខៀវហ្នឹងពេលគេវ៉ៃខ្លាំងគេហូបបាយឆ្ងាញ់សប្បាយខ្លាំងគាត់រឹបហើយ ចឹងបានអស់ពីតា សុន សេនហ្នឹងមកបានចប់បណ្ដោយទាល់តែឥឡូវហ្នឹងមក ។

វណ្ណៈ៖  ម៉េចបានជាពូដឹងថាលោកសុន សេនជួបជាមួយយួន?

ជុន ៖  ចុះគេថាខ្សែត្រូវជាបងប្អូន ។

វណ្ណៈ ចឹងថាខ្មែរបងប្អូនខាងយួន?

ជុនៈ គេថាបងប្អូនខាងយួន ដឹងមែនមិនមែន ។

វណ្ណៈ៖ ចឹងពូឮគេថាទេ?

ជុន ៖ ខ្ញុំឮគេថាដែរ គេថា តា ខៀវ សំផនបែកក្បាល តា សុន សេនមិនបែកក្បាលផង កាលហ្នឹងឮតែគេ និយាយមិនដឹងជាពិតឬមិនមែន ។

វណ្ណៈ៖ តែសុន សេនជាគាត់ជាខ្មែរកម្ពុជាក្រោមដែរ?

ជុន ៖ ចឹង! ចឹងដឹងបានជាចឹង ។

វណ្ណៈ៖ តា សុន សេន និងតា អៀង សារីជាអ្នកកម្ពុជាក្រោមដែរ សុទ្ធតែចេះភាសាយួនហើយ?

ជុន ៖ ចឹង ។

វណ្ណៈ៖ ចឹងតា ម៉ុកអីហ្នឹង គាត់អត់មានមកកាន់ខាងនេះ?

ជុន ៖ អត់ទេ! គាត់នៅកាន់ខាងអន្លង់វែង "ប្រពន្ធគាត់និយាយ" គេថាតា ម៉ុក កាចខ្ញុំថាមិនកាចទេ ខ្ញុំធ្លាប់នៅជាមួយតា ម៉ុកតាំងពី៧៣មក គាត់ស្រួលណាស់ ។

វណ្ណៈ៖ ចឹងឮពាក្យគេនិយាយថា បើសុំនាឡិកាតាម៉ុកឲ្យចឹង នៅពេលមិនទាន់ទៅណាមានម្នាក់ទៀតមកសុំទៀត តា ម៉ុកដោះពីម្នាក់ដែលគាត់ឲ្យហ្នឹងទៅឲ្យម្នាក់ផ្សេងទៀត?

ជុន ៖ តា ម៉ុក ចឹងមែន ដូចថាខ្ញុំអត់មានម៉ោងទេ ខ្ញុំសុំនាឡិកា ចឹងឯងយកទៅ តែលោកគ្រូកុំភ្លេចខ្លួនទៅឲ្យបាត់តែហាននៅហ្នឹងទៀតមានគេមកសុំច្បាស់ជាយកទៅឲ្យអានោះម្តង ព្រោះខ្ញុំនៅជាមួយគាត់តាំងពីឆ្នាំ៧៣ កាលចូលយោធាមុនដំបូងខ្ញុំមិនស្គាល់តា ម៉ុកទេ ខ្ញុំចាប់តា ម៉ុកមកដាក់នៅកងវរៈខ្ញុំ គាត់មិនដែលស្លៀកខោអាវត្រឹមត្រូវទេ ដូចថាកន្លែងមានខបសគ្គចឹងឲ្យយើងយាមចឹងគាត់ធ្វើពិសោធន៍ហើយ ស្លៀកពាក់ខោអាវដូចជាប្រជាជនយើងនៅស្រុកគ្រាំខ្នារចឹងចូលទៅខ្ញុំមានដឹងណាខ្ញុំចាប់ គាត់និយាយថាឲ្យតាចូលមើលបន្តិចទេ ព្រោះផ្ទះឃ្លាំងគ្រាប់ហ្នឹងវាមានបញ្ហាអី ខ្ញុំថាមិនឲ្យចូលទេតា អង្គការមិនឲ្យចូលគាត់ថាមិនអីទេឲ្យតាសុំទៅបន្តិចខ្ញុំថាតាឯងចំនាស់ហ្នឹងហើយមិនខ្លាចស្លាប់ទេ ថាតាមិនខ្លាចស្លាប់ទេឲ្យតាទៅ ខ្ញុំថាតាចង់ស្លាប់ចឹងតាឯងទៅកងវរៈខ្ញុំសិន ចាប់គាត់ដឹកទៅដល់កងវរៈស្រាប់តែឃើញគេលើកដៃសំពះ ដល់ឃើញចឹងខ្ញុំភ័យខ្ញុំថាប៉ុណ្ណឹងខ្ញុំច្បាស់ជាងាប់ហើយលែងបានឃើញមុខម៉ែឪហើយ "លាយប្រពន្ធគាត់និយាយ" ។

វណ្ណៈ៖ ចឹងមានពីណាទៅដឹងមានអី?

ជុន ៖ មានអីគេយាមម្នាក់តែមួយអាទិត្យទេ ខ្ញុំយាមទាល់បែកគ្រាំខ្នារហើយបានទៅស្រែអំបិល តែគាត់ស្រួលត្រង់ចឹង ដូចថាយោធាសុំអីចឹង ដូចថាយោធាថាតា សុំជ្រូក៩ក្បាលមក គាត់ថាចាំ

អញឲ្យពួកសេដ្ឋកិច្ចយកមកឲ្យ យកមក៥ក្បាលទៅ១០ក្បាលឲ្យតែយោធាស៊ី គេថាតាម៉ុកកាចខ្ញុំមិនថាគាត់កាចទេ "លាយប្រពន្ធគាត់និយាយ" ។

វណ្ណៈ បាទ ។

ជុន ៖ អ្នកអត់ស្គាល់តា ម៉ុកហ្នឹងចឹងឯង ពីណាហ៊ាននិយាយជាមួយ ។

វណ្ណៈ យើងមិនដឹងដែរ?

ជុនៈ ចាស"ប្រពន្ធនិយាយ"បើយើងហ៊ានអត់ខ្លាច យើងខ្លាចគាត់សន្កត់ ។

វណ្ណៈ ចឹងសុំកាត់មីងបន្តិចសិនហើយចង់ទៅជួបពូវិញ ចឹងកាលការទៅចរចារតា គា ខៀវ សំផននិងតាសុន សេនទៅមានថ្នាក់ដឹកនាំណាទៅទៀត ទៅភ្នំពេញកាលហ្នឹង?

ជុន ៖ ខ្ញុំមិនមានឃើញមានពីណាទៅទៀតទេ ។

វណ្ណៈ ចឹងឃើញតែសុន សេននិងខៀវ សំផន?

ជុនៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកាលមកវិញហ្នឹងបែកក្បាលតែតាខៀវ សំផន តា សុន សេនមិនអី?

ជុន ៖ បាទ ។

វណ្ណៈ ចឹងខាងនេះគេចាប់សង្ស័យតា សុន សេនដែលឬមួយយ៉ាងម៉េច ខាងប៉ុល ពតចាប់សង្ស័យដែលឬយ៉ាងម៉េច?

ជុន ៖ អាហ្នឹងបែបចឹងដឹងបានជាមានរឿងរ៉ាវ ។

វណ្ណៈ ចឹងនៅពេលតាខៀវ សំផនមកវិញគាត់មាននិយាយអីជាមួយប្រជាជនដែរ?

ជុន ៖ គាត់មកវិញគាត់ប្រជុំឲ្យរៀបចំកំលាំងយោធាឡើងវៃទៀត ។

វណ្ណៈ គាត់មាននិយាយពីរឿងគេវៃគាត់ទេ?

ជុនៈ ហ្នឹងហើយគប់គាត់ថាឥឡូវយើងចរចាមិនត្រូវគ្នាទេ គេមិនព្រមទេ ចឹងយើងមានតែតស៊ូទៅទៀត បើមិនចឹងទេបាត់ទឹកដីអស់ឥឡូវហើយចឹងទៅជាមួយគេឯងទៅទៀតទៅ ។

វណ្ណៈ បាទ ។

ជុន ៖ ដល់ហើយគាត់បើកសម្ភារៈឲ្យទៀតមានអង្រឹងសាក់កាដូអីហ្នឹង ទាំងយប់ទាំងថ្ងៃទៅ ។

វណ្ណៈ ចឹងគាត់ត្រឡប់មកម៉ាឡៃ?

ជុន ៖ បាទ ។

វណ្ណៈ ចឹងគាត់ថាត្រូវវៃតទៀត?

ជុនៈ ហ្នឹងហើយ ។

វណ្ណៈ ព្រោះខ្លាចបាត់ទឹកដី?

ជុនៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកាលក្រោយមកយើងមានការចរចារឆ្នាំ៩២មានអ៊ុន គាត់មកដល់នេះទេ?

ជុន ៈ អត់ហ៊ានមកទេ ។

វណ្ណៈ មកត្រឹមខេត្តៗ?

ជុនៈ មានមកដែលឲ្យមកពីក្រោយតែយើងបើចង់មកឲ្យមកពីមុនមកចំមុខមានអីខ្លះ មានខបស័គ្គអីខ្លះ ខាងក្នុងនិងខាងនេះមាននរណាហ៊ានបាញ់មុន បើមកខាងនេះបាញ់ឬខាងនោះ បាញ់ចង់ដឹងចេះ ដល់នេះទៅពួកអ៊ុនគាត់អន្តរជាតិត្រឹមត្រូវមែនមករៀបចំស្រុកខ្មែរ ។

វណ្ណៈ ចឹងអត់មានអ៊ុន គាត់ចូលមកដល់ទេ?

ជុន ៈ អត់មានចូលទេ ថាចូលៗមកពីក្រោយ ។

វណ្ណៈ បាទ ។

ជុនៈ គេថាមិនចូលមកទេ
ពីមុនមិនហ៊ានមកទខ្លាចខាងនេះហើយខាងនេះថានរណាបាញ់មុននរណាហ៊ានសម្លាប់មុនអាហ្នឹងឲ្យ ដឹងចាំមើលណាល្អនរណាអាក្រក់អត់មកដល់មកៗពីក្រោយ បើមកពីក្រោយមិនបាច់មកទេ ។

វណ្ណៈ ចឹងនៅតំបន់ម៉ាឡៃមិនបានបោះឆ្នោតទេ?

ជុន ៈ អត់ទេ ។

វណ្ណៈ ចឹងកាលបោះឆ្នោតឆ្នាំ៩៣អត់បានទេ?

ជុនៈ បាទ ។

វណ្ណៈ ចឹងអាណាត់ទី២មានបានបោះឆ្នោតទេ?

ជុន ៈ អាណាត់ទី២មានបានបោះឆ្នោតខ្លះ មិនបានបោះទូទៅទេ ។

វណ្ណៈ ចឹងបោះខ្លះ?

ជុនៈ ហ្នឹងហើយកាលហ្នឹងបោះនៅខាងក្នុងហ្នឹងទេ លើកទី៣បានចាប់ផ្តើម ។

វណ្ណៈ ចឹងនៅសមាហរណកម្មហើយពូគិតថាវាណាស្រួលជាងមុន ឬកាលមិនទាន់សមាហរណ៍កម្មស្រួល ជាងយ៉ាងម៉េច?

ជុន ៈ ឥឡូវនេះស្រួលជាង មានសិទ្ធចង់ទៅលេងឯណាដើរទៅចង់ធ្វើកសាងអីស្រួល ចង់រកស៊ីធ្វើស្រែ ចំការអីជីវភាពដោះស្រាយអីអត់មានពិបាកស្មុគ ស្មាញអីថាទៅរកអានេះប៉ះអានោះអីអត់មាន គេចាប់គេចងអត់មានទេ យើងមានច្បាប់ទំលាប់ត្រឹមត្រូវល្អ ។

វណ្ណៈ ឥឡូវនេះនៅតំបន់ម៉ាឡៃនេះ គេច្រើនតែនិយាយថាជាតំបន់ខ្មែរក្រហមអីចឹង ចឹងពូមានគំនិត ផ្សះផ្សារកុំឲ្យមានការបែងចែកអីចឹង ថាខ្មែរខាងក្នុងខ្មែរខាងក្រៅអីចឹងតទៅទៀតទេ?

ជុន ៖ ខ្ញុំមិនចង់ឲ្យមានខ្មែរបែកជាចែកជាពីរបីអីទេ វាលំបាកណាស់ ចង់ឲ្យមានខ្មែរតែមួយ ។

វណ្ណៈ ចឹងចង់ឲ្យមានខ្មែរតែមួយ?

ជុន ៖ ចង់ឲ្យមានខ្មែរតែមួយ កុំឲ្យប្រកាន់ថាខ្មែរព្រំដែន ខ្មែរក្រហមចាស់ឬខាងក្នុងនេះកុំឲ្យមានបញ្ហា មិនចង់ឲ្យមានទេ ចង់ឲ្យមានខ្មែរតែមួយតែម្តង អ្នកនៅនេះក៏មិនចង់ធ្វើខ្មែរក្រហមខាងនោះអីឲ្យ មានខ្មែរតែមួយតែម្តង ។

វណ្ណៈ បាទ ។

ជុន ៖ ចង់ឲ្យខ្មែរខាងក្នុងហ្នឹងនៅនេះក៏ខ្មែរដូចតែគ្នាទេ មិនបាច់ថានៅនេះខ្មែរក្រហមនៅនោះខ្មែរធម្មតា អីអត់ទេ ឲ្យមានខ្មែរដូចតែគ្នាទាំងអស់ ពីមុនចេះតែ អើការសម័យតស៊ូក្នុងព្រៃកាលនោះចេះ តែរៀលគ្នាហើយ ។

វណ្ណៈ បាទ ។

ជុនៈ អានេះថាចេះ អានោះ ចឹងអាណាល្អអាក្រក់អាណាត្រូវអាណាមិនត្រូវអត់ដឹង ។

វណ្ណៈ ចឹងទាក់ទងចឹងដែលសំនួរចុងក្រោយខ្ញុំសួរពូថានៅពេលដែលស្រុកយើងស្រួលបួរមានសន្តិភាព ទូទាំងប្រទេសចឹងហើយកើតមានតុលាការមួយដែលតុលាការហ្នឹងជាតុលាការខ្មាតអន្តរជាតិ ចូលរួមជាមួយតុលាការកម្ពុជាយើងសព្វថ្ងៃនេះណាស់?

ជុន ៖ បាទ ។

វណ្ណៈ ចឹងនៅពេលមានតុលាការកាត់ទោសជនាន់អ្នកដឹកនាំដែលធ្វើឲ្យប្រជាជនស្លាប់ច្រើន ទោះបីថា គាត់មិនបានដឹងពុក្នុងសម័យហ្នឹង តែនៅពេលគាត់ដឹកនាំប្រជាជនស្លាប់ច្រើនចឹង ចឹងពូចង់ឲ្យ មានតុលាការឬមិនចង់ឲ្យមានតុលាការទេ?

ជុន ៖ ខ្ញុំថាមានតុលាការចឹងត្រឹមត្រូវហើយមិនអីទេ សង្គមមួយៗត្រូវតែមានតុលាការចឹងហើយ បើ អត់មានដូចសម័យនោះឃើញទេមានគ្រោះថ្នាក់ច្រើនណាស់ ។

វណ្ណៈ ចឹងមានន័យថាមានតុលាការត្រឹមត្រូវ?

ជុន ៖ មានតុលាការត្រឹមត្រូវ កាលសម័យអត់មានតុលាការអត់មានច្បាប់ហ្នឹងហើយបានជាមាន មនុស្សស្លាប់ អត់មានបុសគល់ចង់បាញ់ៗចង់សម្លាប់ ណាមានលុយចង់សម្លាប់ពីណាក៏បានបើ មានច្បាប់ទោះ បីអ្នកឯងមានថ្នាក់ណាក៏ ដោយមានដល់កំពូលណាកដោយ៏ត្រូវគោរពច្បាប់ដែរ មានច្បាប់វាល្អ ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយដែលបានផ្តល់បទសម្ភាសន៍ខាងខ្ញុំ ។

ជុន ៖ បាទ! អាសាមកលេងអ្នកម៉ាឡែផង ។

វណ្ណៈ បាទ ។

«ចប់»